## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
## នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Dec-2011, 15:30
CMS/CFO: Kauv Keoratanak

### ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់នឹងបញ្ជីឯកសារ សម្រាប់សវនាការវគ្គដំបូង

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ:

នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS

លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក គង់ សំអុន
លោក Jacques VERGÈS

# I. សេចក្តីផ្តើម

១- នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់ *សេចក្តីជូនដំណឹងអំពីឯកសារដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញទាំងឡាយដែលអាចនឹងត្រូវកោះហៅក្នុងអំឡុងពេលបីសប្តាហ៍ដំបូងនៃសវនាការ ជាមួយនឹងឧបសម្ព័ន្ធ ក សម្ងាត់* របស់ខ្លួន (“បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា”)[1]។ តាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង បើសិនជាមានការជំទាស់ទៅនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ត្រូវដាក់ការជំទាស់នោះ ក្នុងរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹង។ ក្រុមមេធាវីការពារក្តី អៀង សារី, ខៀវ សំផន និង នួន ជា (ហៅរួមថា “មេធាវីការពារក្តី”) បានដាក់ការជំទាស់ដែលមានលក្ខណៈទូទៅពេក ដោយតវ៉ាថា ពួកគេមិនអាចផ្តល់ការជំទាស់ជាក់លាក់ និងមានសំអាងហេតុចំពោះបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាបានទេ ដោយសារតែចំនួនឯកសារដែលបានចុះក្នុងបញ្ជី និងពេលវេលាដែលមានៗកម្រិត។

២- ដើម្បីឆ្លើយតប សហព្រះរាជអាជ្ញាជំទាស់ថា (១) គេគ្មានយុត្តិកម្មសម្រាប់ការខកខានដោយមេធាវីការពារក្តី ក្នុងការផ្តល់ការជំទាស់ដែលមានភាពជាក់លាក់ និងមានសំអាងហេតុត្រឹមត្រូវ ទៅនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាឡើយ និង (២) ការជំទាស់ដែលមានលក្ខណៈទូទៅដែលបានបញ្ជូនដោយមេធាវីការពារក្តីនេះ គ្មានសំអាងទេ ហើយមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវ ដូចមានចែងនៅក្នុងវិធាន ៨៧(៣) សម្រាប់ការច្រានចោលភ័ស្តុតាង។

៣- សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង (១) បង្គាប់ទៅមេធាវីការពារក្តីដាក់ឡើងវិញត្រឹមថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ នូវការជំទាស់ដែលមានភាពជាក់លាក់ បើសិនជាមាន ទៅនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដោយកំណត់អត្តសញ្ញាណឯកសារចំៗ ដែលខ្លួនបានជំទាស់ និងសំអាងហេតុនៃការជំទាស់នោះ; (២) ទទួលយកឯកសារដែលមានក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាដែលមិនស្ថិតក្រោមការជំទាស់ជាក់លាក់ណាមួយ និងមានសំអាងហេតុត្រឹមត្រូវ និង (៣) កំណត់ពេលសម្រាប់សវនាការមួយសម្រាប់ការទាញហេតុផលផ្ទាល់មាត់អំពីការជំទាស់ជាក់លាក់ និងដែលមានសំអាងហេតុដែលបានទទួល។ សហព្រះរាជអាជ្ញា ក៏សូមឆ្លៀតយកឱកាសនេះ

[1] **E131/1/4** និង **E131/1/4.1** បញ្ជីឯកសារ, ១ វិច្ឆិកា ២០១១ ។

ផងដែរ ដើម្បីជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងគូភាគីនានាថា សហព្រះរាជអាជ្ញាក្នុងពេលឆាប់ៗខាងមុខនេះ នឹងដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរមួយ ដោយអនុលោមតាមវិធាន៩២ ដែលកំណត់អំពីភស្តុតាងបង្ហាញអំពីភាពជឿទុកចិត្តចំពោះឯកសារដែលបានដាក់បញ្ចូលក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា។

## II. ប្រវត្តិនីតិវិធី

៤- នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យគូភាគីដាក់បញ្ជីឯកសារដែលខ្លួនមានបំណងចង់ពឹងផ្អែកនៅពេលសវនាការជំនុំជម្រះ[2]។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសាររបស់ខ្លួន រួមបញ្ចូលឯកសារចំនួន៦៤៨៨[3]។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ក្នុងអម្លុងពេលសវនាការបឋមសម្រាប់សំណុំរឿង០០២ អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឲ្យគូភាគីកំណត់អត្តសញ្ញាណឯកសារ និងវត្ថុតាងផ្សេងៗដែលខ្លួនពិចារណាថាពាក់ព័ន្ធនឹងដំណាក់ដំបូងនៃសវនាការ("បញ្ជីឯកសារដំណាក់កាលដំបូង")[4]។នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសារដំណាក់កាលដំបូងរបស់ខ្លួន រួមមានឯកសារចំនួន៤៧៦៨[5]។

៥- នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ បន្ទាប់ពីការមានបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២[6] ទៅជាឈុតនៃករណីតូចៗ និងការកំណត់ពេលសវនាការនៃការជំនុំជម្រះដំបូង[7] អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយ ដោយបង្គាប់ឲ្យគូភាគីបញ្ជាក់មិនឲ្យហួសពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១ អំពីឯកសារ និងវត្ថុតាងផ្សេងៗពីបញ្ជីឯកសារដំណាក់កាលដំបូងរបស់ខ្លួន ដែលពួកគេចង់ឲ្យទទួលយកពាក់ព័ន្ធនឹងសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដែលអាចនឹងត្រូវកោះហៅក្នុងអម្លុង

[2] **E9** ដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដាក់សម្ភារៈក្នុងការរៀបចំសវនាការ, ១៧ មេសា ២០១១ ។

[3] **E9/31** បញ្ជីឯកសារសវនាការរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន៨០(៣), ១៩ មេសា ២០១១ ("បញ្ជីឯកសារតាមវិធាន៨០(៣)")។

[4] **E1/4.1** ប្រតិចារឹកសវនាការបឋម សាធារណៈ, ២៧ មិថុនា ២០១១ ត្រង់ទំព័រទី២៥ ។

[5] **E109/4** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង សុំឯកសារពាក់ព័ន្ធនឹងដំណាក់កាលដំបូងនៃសវនាការ, ២២ កក្កដា ២០១១ និងឯកសារភ្ជាប់ទៅនឹងចម្លើយតបនេះ **E109/4.1-4.20** ("បញ្ជីឯកសារដំណាក់កាលដំបូង") ។

[6] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, ២២ កញ្ញា ២០១១ ។

[7] **E131** ដីកាកំណត់កាលបរិច្ឆេទការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២, ១៨ តុលា ២០១១ ។

ពេលវគ្គទីមួយនៃសវនាការដំបូង[8]។ អនុស្សរណៈនេះ បានបង្គាប់បន្ថែមឱ្យគូភាគីដាក់ការជំទាស់ បើសិនជាមាន ទៅនឹងបញ្ជីឯកសារ និងវត្ថុតាងរបស់ភាគីដទៃ ក្នុងរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹង។ គូភាគីត្រូវបានបង្គាប់ឱ្យដាក់ការជំទាស់ដែលជាក់លាក់ និងចំៗចំពោះឯកសារ ឬជំពូកឯកសារនិមួយៗដែលពួកគេបានតវ៉ា ស្របតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវិធាន៨៧(៣)[9]។

៦- នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសាររបស់ខ្លួន ដោយកំណត់អត្តសញ្ញាណឯកសារចំនួន៩៧៨ ដែលខ្លួនចង់ឱ្យទទួលយកពាក់ព័ន្ធនឹងសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដែលអាចនឹងត្រូវកោះហៅ ក្នុងអម្លុងពេលបីសប្ដាហ៍ដំបូងនៃសវនាការ[10]។ ក្នុងចំនួនឯកសារទាំង ៩៧៨ មានឯកសារតែប្រាំបួនប៉ុណ្ណោះដែលមិនទាន់បានដាក់បញ្ចូលពីមុន នៅក្នុងបញ្ជីឯកសារ អនុលោមតាមវិធាន៨០(៣) និងបញ្ជីឯកសារដំណាក់កាលដំបូងរបស់សហព្រះរាជអាជ្ញា[11]។ ក្នុងចំណោមឯកសារទាំងប្រាំបួននេះ មានឯកសារតែបីប៉ុណ្ណោះដែលមិនមាននៅក្នុងសំណុំរឿង ប៉ុន្តែនៅពេលនេះឯកសារទាំងនេះ អាចឱ្យគូភាគីទាំងអស់រកបានហើយនៅក្នុងឃ្លាំងផ្ទុកឯកសាររួម។

៧- នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១១ មេធាវីការពារក្ដី អៀង សារី បានសរសេរលិខិតមួយច្បាប់ផ្ញើជូនមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង ដោយជំទាស់នឹងឯកសារទាំងអស់ដែលមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាដែលមិន "ជាប់ពាក់ព័ន្ធដោយផ្ទាល់" ទៅនឹងសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលអាចនឹងត្រូវកោះហៅនៅក្នុងអម្លុងពេលបីសប្ដាហ៍ដំបូងនៃសវនាការ ដោយថ្លែងថា ពួកគេមិនអាចផ្ដល់ការជំទាស់ដែលមានសំអាងហេតុបានទេ និងបានគូសបញ្ជាក់ពីការនៅប្រកាន់យកការជំទាស់ទូទៅរបស់ អៀង សារី ដែលបានដាក់ពីមុន ទៅនឹងប្រភេទឯកសារខុសៗគ្នាជាច្រើន[12]។ លិខិតនេះបានស្នើឱ្យមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ បញ្ជាក់អះ

---

[8] **E131/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា *បញ្ជីសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5*; ២៥ តុលា ២០១១ (ការផ្ដល់ជូនច្បាប់ចម្លងនៃអនុស្សរណៈនេះជាមុនគ្រាន់ជាការគួរសម ត្រូវបានទំនាក់ទំនងមកកាន់គូភាគីនានានៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១) ("អនុស្សរណៈ")។

[9] *ក្នុងឯកសារដដែលដូចខាងលើ* ។

[10] **E131/1/4** បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា, កំណត់សម្គាល់*ខាងដើម* លេខ១ ។

[11] *ក្នុងឯកសារដដែលដូចខាងលើ* ត្រង់កំណត់សម្គាល់លេខ៩ ។

[12] លិខិតផ្ញើជូន Susan Lamb ដាក់ចំណងជើងថា *ការជូនដំណឹងពាក់ព័ន្ធនឹងការជំទាស់របស់ អៀង សារី ទៅនឹងឯកសាររបស់ កសព និងភាគីដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់រយៈពេលបីសប្ដាហ៍ដំបូងនៃសវនាការ (២៨ វិច្ឆិកា - ១៦ ធ្នូ ២០១១)*, ៤ វិច្ឆិកា ២០១១ ("ការជំទាស់

អាងថា តើសេចក្តីជូនដំណឹងអំពីការជំទាស់ជាផ្លូវការទៅនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា នៅតែចាំបាច់ឲ្យមាន ត្រឹមថ្ងៃកំណត់ចុងក្រោយដែរ ឬទេ[13]។ សហព្រះរាជអាជ្ញាមិនបានដឹងថាតើមានចម្លើយតបណាមួយទៅនឹងលិខិតនេះទេ ហើយមកដល់ពេលនេះ គ្មានការជំទាស់ជាផ្លូវការណាមួយទៅនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាត្រូវបានដាក់ដោយ អៀង សារី ឡើយ។ ទន្ទឹមនេះ លិខិតចុះកាលបរិច្ឆេទថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១១នេះ ត្រូវបានចាត់ទុកថាជាការប្រមូលផ្តុំបញ្ចូលគ្នានៃការជំទាស់របស់ អៀង សារី ទៅនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា។ ដូចដែលសហព្រះរាជអាជ្ញាបានឆ្លើយតបរួចហើយ ទៅនឹងការជំទាស់ជាទូទៅពីដំបូងរបស់ អៀង សារី ដែលបានបង្រួមបញ្ចូលគ្នាជាសេចក្តីយោងបញ្ចូលក្នុងលិខិតនេះ[14] សហព្រះរាជអាជ្ញានឹងមិនលើកម្តងទៀតនៅក្នុងចម្លើយតបនេះទេ វៀរលែងតែមានករណីជាន់គ្នាជាមួយនឹងការជំទាស់ដែលបានដាក់ដោយមេធាវីការពារក្តីក្រុមផ្សេង។

៨- នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ខៀវ សំផន បានដាក់ការជំទាស់ទៅនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដែលនៅក្នុងនោះ គាត់បានជំទាស់ទៅនឹងឯកសារទាំងអស់ដែលមិនពាក់ព័ន្ធទៅនឹងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចនឹងត្រូវកោះហៅ នៅក្នុងអម្លុងពេលបីសប្តាហ៍ដំបូងនៃសវនាការ[15]។ ដោយមានការអត្ថាធិប្បាយថាគេ "មិនអាច" ដាក់ការជំទាស់ទៅនឹងឯកសារជាក់លាក់ណាមួយ គាត់បែរជាដាក់ការជំទាស់ដែលមានលក្ខណៈទូទៅទៅនឹងជំពូកឯកសារជាច្រើនខុសៗគ្នា រួមមាន ឯកសារដែលទទួលបានតាមការធ្វើទារុណកម្ម កំណត់ហេតុសាក្សីពីមុន សម្ភារៈមិនកើតឡើងដំណាលគ្នា (មានដូចជា សៀវភៅ របាយការណ៍វិភាគ ខ្សែភាពយន្ត) អត្ថបទសារព័ត៌មាន ឯកសារដែលមិនអាចពិនិត្យបាន និងឯកសារដែលបានប្រមូលដោយមជ្ឈមណ្ឌល DC-Cam។

---

របស់ អៀង សារី") ដោយយោងឯកសារ **E114** ការជំទាស់របស់ អៀង សារី ទៅនឹងការទទួលយកប្រភេទឯកសារជាក់លាក់មួយចំនួន, ៦ កញ្ញា ២០១១ ("ការជំទាស់ពីមុនរបស់ អៀង សារី") ។

[13] ដូចដែលបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ត្រូវបានគេជូនដំណឹងដល់គូភាគីនានា នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១១ នោះពេលវេលាកំណត់សម្រាប់ការឈប់ទទួលយកការដាក់ការជំទាស់ គឺនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ។

[14] **E114/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "ការជំទាស់របស់ អៀង សារី ទៅនឹងការទទួលយកប្រភេទឯកសារជាក់លាក់មួយចំនួន", ១៦ កញ្ញា ២០១១ ("ចម្លើយតបទៅនឹងការជំទាស់ពីមុនរបស់ អៀង សារី") ។

[15] **E131/6** Exceptions d'irrecevabilité portent sur les listes de documents présentées par les autres parties pour la première session du premier procès, ១៤ វិច្ឆិកា ២០១១ (បានជូនដំណឹងជាភាសាបារាំងនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ និងជាភាសាអង់គ្លេស នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១) ("ការជំទាស់របស់ ខៀវ សំផន") ។ មកដល់ថ្ងៃនេះ ការជំទាស់របស់ ខៀវ សំផន នេះជាភាសាខ្មែរ នៅមិនទាន់ត្រូវបានគេជូនដំណឹងនៅឡើយ ។

៩- នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ នេះដែរ នួន ជា បានដាក់*ការជំទាស់ សេចក្តីសង្កេត និងការជូនដំណឹងទាក់ទងនឹងឯកសារខុសៗគ្នាដែលនឹងត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង* របស់ខ្លួន ("ការជំទាស់របស់ នួន ជា")[16]។ នៅក្នុងឯកសារនេះ នួន ជា បានជំទាស់ទៅនឹងការទទួលយកឯកសារណាក៏ដោយដែលយថាភូតនៃឯកសារនោះមិនទាន់បានកំណត់ច្បាស់លាស់។ បន្តមកទៀត គាត់ប្រកាន់យកតាមជំហរក្រុមមេធាវីការពារក្តី អៀង សារី និង អៀង ធីរិទ្ធ (ដូចបានបញ្ជាក់នៅក្នុងលិខិតផ្ញើជូនមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់)[17] ទាក់ទងនឹងការដាក់ការជំទាស់ដែលមានភាពជាក់លាក់ និងមានសំអាងហេតុដោយនិយាយថាគេ "មិនអាច"ធ្វើបានទេ នៅក្នុងថិរវេលាមួយដូចបានកំណត់បែងចែកដូច្នេះ។

១០- ដោយសារតែសភាពរួមនៃបញ្ហាដែលបានលើកដោយមេធាវីការពារក្តី សហព្រះរាជអាជ្ញាសូមដាក់ចម្លើយតបរួមមួយទៅនឹងការដាក់ឯកសារខុសៗគ្នារបស់ពួកគេ (ក្នុងករណី ខៀវ សំផន និង នួន ជា) និងលិខិត (ក្នុងករណី អៀង សារី)។ ដោយសារការជំទាស់របស់ នួន ជា ច្បាប់ជាភាសាខ្មែរ ត្រូវបានជូនដំណឹងនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាចាត់ទុកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ ជាថ្ងៃផុតកំណត់ចុងក្រោយសម្រាប់ការដាក់ចម្លើយតប។ ប៉ុន្តែ គេមានការកត់សំគាល់ថាមកដល់ថ្ងៃដាក់ចម្លើយតបនេះហើយ គេនៅតែមិនអាចរកបាននូវការជំទាស់របស់ អៀង សារី និងខៀវ សំផន ច្បាប់ជាភាសាខ្មែរនៅឡើយ។

១១- នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយដែលថ្លែងថា នៅពេលចាប់ផ្តើមសួរដេញដោលជនជាប់ចោទ ខ្លួននឹងអានកថាខណ្ឌដូចខាងក្រោមនេះ ដែលយកចេញពីដីកាដំណោះស្រាយ: កថាខ័ណ្ឌទី១៨-៣២, ៨៦២-៨៦៨, ១៥៧៧-១៨៥០, ១១២៦-១១៣០ និង ១៥៩៨-១៦០០។ អនុស្សរណៈបានអះអាងថា បើមិនមានដីកាសម្រេចបន្ថែមណាមួយទៀតទេ ឯកសារគាំទ្រដែលបានយោងនៅក្នុងកំណត់សំគាល់ចុងទំព័រនៃកថាខ័ណ្ឌទាំងនេះ នឹងត្រូវពិចារណា

---

[16] **E131/1/9** ការជំទាស់របស់ នួន ជា, ១៤ វិច្ឆិកា ២០១១ (បានជូនដំណឹងជាភាសាអង់គ្លេស នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ និង ជាភាសាខ្មែរ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១) ។

[17] ការជំទាស់របស់ អៀង សារី, កំណត់សម្គាល់*ខាងដើម* លេខ១២ ។ លិខិតពីមេធាវីការពារក្តី អៀង ធីរិទ្ធ ផ្ញើជូនមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ ដែលមានចំណងជើងថា *សេចក្តីជូនដំណឹងពាក់ព័ន្ធនឹងការជំទាស់របស់ អៀង ធីរិទ្ធ ទៅនឹងឯកសាររបស់ កសព និងភាគីដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់រយៈពេលបីសប្តាហ៍ដំបូងនៃសវនាការ (២៨ វិច្ឆិកា - ១៦ ធ្នូ ២០១១)*, ៨ វិច្ឆិកា ២០១១ ។

ថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះស្របតាមវិធាន៨៧[18]។ មានឯកសារចំនួន១២៤ ត្រូវបានលើកយោងក្នុងកំណត់សំគាល់ចុងទំព័រដែលពាក់ព័ន្ធ ដែលក្នុងនោះមានឯកសារចំនួន៥៣ ត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា។ ឯកសារទាំង៥៣ នេះត្រូវបានចុះបញ្ជីនៅក្នុងឧបសម្ព័ន្ធ ក ភ្ជាប់នឹងចម្លើយតបនេះ ដែលបានរៀបចំឡើងទៅតាមប្រភេទឯកសារ។

## III. អំណះអំណាង

### ក. គេគ្មានយុត្តិកម្មសម្រាប់ការខកខានដោយមេធាវីការពារក្តីក្នុងការផ្តល់ការជំទាស់ដែលមានភាពជាក់លាក់ និងមានសំអាងហេតុត្រឹមត្រូវ ទៅនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាឡើយ

១២- អនុស្សរណៈផ្តល់ជូនគូភាគីនូវការណែនាំពីអ្វីដែលត្រូវធ្វើ នៅពេលមានការជំទាស់ទៅនឹងឯកសារ ឬវត្ថុតាងរបស់ភាគីមួយផ្សេងទៀត។ ការណ៍នេះមានរាប់បញ្ចូលទាំងលក្ខខណ្ឌតម្រូវឲ្យ "បញ្ជាក់ដោយសង្ខេប ពាក់ព័ន្ធនឹងឯកសារ ឬវត្ថុតាងនិមួយៗ ឬប្រភេទឯកសារ ឬវត្ថុតាងដែលតវ៉ា ការជំទាស់តវ៉ាជាក់លាក់ដែលបានលើកឡើង"[19] និងបញ្ជាក់ពីមូលដ្ឋាននៃការជំទាស់និមួយៗ ដោយយោងវិធាន៨៧(៣)[20]។

១៣- មេធាវីការពារក្តីតវ៉ាថា ពួកគេមិនអាចដាក់ជូនការជំទាស់ជាក់លាក់ និងមានសំអាងហេតុទៅនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា នៅក្នុងរយៈពេល១០ថ្ងៃដែលបានលៃទុកបានទេ។ ដោយប្រើជាយុត្តិកម្មរបស់ខ្លួន ពួកគេបានចង្អុលទៅរកចំនួនដ៏ច្រើននៃឯកសារនៅលើបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា រួមជាមួយនឹងបញ្ជីឯកសារដែលបានដាក់ដោយភាគីដើមបណ្តឹងរដ្ឋប្បវេណី។ ដោយការបូកបញ្ចូលគ្នានៃបញ្ជីឯកសារទាំងពីរ មេធាវីការពារក្តីស្វែងរកដើម្បីបង្កើតចំណាប់អារម្មណ៍ថាការងារពិនិត្យឡើងវិញ និងបង្កើតការជំទាស់ទៅនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា គឺធំធេងជាងអ្វីដែលមាន។ ការពិត បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដាក់បញ្ចូលប្រហែល៧ដង តិចជាងចំនួនឯកសារនៃបញ្ជីឯកសាររបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងដូចដែលបានទទួលស្គាល់ក្នុងការជំទាស់របស់ អៀង សារី[21] បានកំណត់អត្តសញ្ញាណតាមប្រភេទ និងចំណុចពាក់ព័ន្ធនៃដីកា

---

[18] **E141** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ១៧ វិច្ឆិកា ឆ្នាំ២០១១, ត្រង់ទំព័រទី២-៣ ។

[19] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ត្រង់ទំព័រទី២ ។

[20] *ឯកសារដែលដូចខាងលើ*, ត្រង់ទំព័រទី២ ។

[21] ការជំទាស់របស់ អៀង សារី, កំណត់សម្គាល់*ខាងដើម*លេខ១២ ត្រង់ទំព័រទី១ ។

បញ្ជូនរឿងទៅជំនុំជម្រះ។ បញ្ជីឯកសារនេះក៏បញ្ចូលផងដែរនូវសេចក្តីរៀបរាប់នៃឯកសារនិមួយៗ សេចក្តីសង្ខេបខ្លឹមសាររបស់វា និងអង្គហេតុដែលចង់បញ្ជាក់។

១៤- ការពិតដែលបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា បានដាក់បញ្ចូលឯកសារចំនួន៩៧៨ មិនមែនជាលេសស្របច្បាប់ចំពោះការខកខានរបស់មេធាវីការពារក្តី ក្នុងការចាត់សកម្មភាពអ្វីមួយទេ និងក៏មិនគួរមេធាវីការពារក្តីមានការភ្ញាក់ផ្អើលដែរ ដោយសារខ្លួនបានចូលរួមក្នុងសំណុំរឿងនេះ៤ឆ្នាំមកហើយ ដឹងថាសហព្រះរាជអាជ្ញា ស្វែងរកដើម្បីបង្ហាញឯកសារដ៏ច្រើនដូច្នេះដោយហេតុតែទំហំនៃករណីនេះ និងបន្ទុកនៃការបង្ហាញរបស់ខ្លួន។

១៥- ដូចដែលបានធ្វើការកត់សំគាល់ពីដំបូង គឺមានឯកសារតែប្រាំបួនក្នុងចំណោមឯកសារទាំងអស់ដែលមាននៅក្នុងបញ្ជីបច្ចុប្បន្ន ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៨០(៣)នៃវិធានផ្ទៃក្នុង ដែលបានដាក់កាលពីក្នុងខែមេសា ឆ្នាំ២០១១ និងបញ្ជីឯកសារសម្រាប់សវនាការលើកទី១ ដែលបានដាក់នៅខែកក្កដា ឆ្នាំ២០១១។ គ្រាន់តែជាការមិនគួរឲ្យជឿទេថា មេធាវីការពារក្តី អស់ពេលជាងប្រាំមួយខែបន្ទាប់ពីបន្ទាប់ពីការដាក់ឯកសារដោយសហព្រះរាជអាជ្ញា លើកទីមួយហើយថាពួកគេនៅមិនទាន់ត្រូវបានផ្តល់នូវសេចក្តីជូនដំណឹងគ្រប់គ្រាន់អំពីឯកសារទាំងឡាយដែលសហព្រះរាជអាជ្ញា ខំប្រឹងស្វែងរកដើម្បីពឹងផ្អែកឬក៏ សហព្រះរាជអាជ្ញាមិនត្រូវបានគេផ្តល់ពេលវេលាឲ្យបានគ្រប់គ្រាន់ ដើម្បីពិនិត្យ និងពិចារណាឡើងវិញដើម្បីធ្វើអញ្ញត្រកម្មប្រឆាំងនឹងឯកសារទាំងនេះ ជាពិសេសដោយសារតែបញ្ជីឯកសារបច្ចុប្បន្ននេះ គឺតំណាងឲ្យចំនួនតែ១៥% នៃបញ្ជីឯកសារដើមប៉ុណ្ណោះ។ លើសពីនេះ បើសិនជាមេធាវីការពារក្តីមានការព្រួយបារម្ភចំពោះការគ្មានពេលវេលាពិតប្រាកដមែននោះ ដំណោះស្រាយតាមផ្លូវច្បាប់គឺគួរតែបានធ្វើសំណើដើម្បីសុំឲ្យពន្យារពេលកំណត់វិញ ទើបវាប្រសើរជាងការខកខានមិនបានអនុវត្តតាមការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង។

១៦- អៀង សារី ក៏បានរក្សាគំនិតដដែលថា មិនអាចមានលទ្ធភាពក្នុងការដាក់ជូននូវអញ្ញត្រកម្មដោយមានការបញ្ជាក់មូលហេតុបានទេ ពីព្រោះបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាមិនបានបញ្ជាក់អត្តសញ្ញាណថាតើឯកសារណាខ្លះដែលនឹងត្រូវដាក់សម្រាប់សាក្សីនីមួយៗ ដែលត្រូវកោះហៅនៅក្នុងអំឡុងពេលនៃសវនាការលើកដំបូង។ ការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង បានដាក់បញ្ចូលនូវ

លក្ខខណ្ឌតម្រូវបែបនេះ ដោយនិយាយចំៗ ឬមួយក៏ដោយបង្កប់ន័យ។ នេះគឺកើតចេញមកអំពីការពិតដែលថា គ្មានក្រុមមេធាវីការពារក្តីណាមួយក្នុងចំណោមក្រុមមេធាវីការពារក្តីទាំងនេះបានដាក់បញ្ជីឯកសារ[22] ដើម្បីឆ្លើយតបទៅនឹងការណែនាំឲ្យបញ្ជាក់អំពីថាតើឯកសារណាត្រូវដាក់សម្រាប់សាក្សីណា។ នៅក្នុងឧទាហរណ៍យ៉ាងច្បាស់មួយអំពីការអនុវត្តពីរខុសគ្នាលើបទដ្ឋានតែមួយ អៀង សារី បានខិតខំព្យាយាមប្រកែកតវ៉ាថា គឺជាអរូបីដែលថា ឯកសាររបស់គាត់មិនបានបញ្ជាក់អត្តសញ្ញាណនៃឯកសារទៅតាមសាក្សី ព្រោះថា វាមានលក្ខណៈ "ប្រត្យក្សសម្រាប់អ្នកណាមួយដែលពិនិត្យមើលឡើងវិញនូវឯកសារទាំងឡាយដែលនៅក្នុងបញ្ជីរបស់យើង តើឯកសារណាទាក់ទងទៅនឹងសាក្សីណា"។ ការប្រើប្រាស់ជាមូលដ្ឋាននៃ*ការយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់* ដោយក្រុមមេធាវីការពារក្តី អៀង សារី ដែលបានចូលរួមនៅក្នុងសំណុំរឿងនេះបួនឆ្នាំមកហើយ និងមានសិទ្ធិពិនិត្យគ្រប់ចំណែកនិមួយៗនៃភ័ស្តុតាងដែលបានដាក់នៅក្នុងសំណុំរឿង (ក្នុងរបៀបដូចគ្នានឹងសហព្រះរាជអាជ្ញា) ត្រូវតែមានពេលវេលាគ្រប់គ្រាន់ដើម្បីបានដឹងជាប្រាកដថា តើសាក្សីណាមួយដែលខ្លួនអាចនឹងផ្តល់យោបល់ទៅនឹងប្រភេទឯកសារណាមួយ។

## ខ. អញ្ញត្រកម្ម គឺផ្អែកលើមូលដ្ឋានគ្មានសម្អាងហេតុ

### *i. អញ្ញត្រកម្មចំពោះឯកសារនានា "ដែលមិនទាក់ទងដោយផ្ទាល់" ទៅនឹងសាក្សី*

១៧- អៀង សារី និង ខៀវ សំផន បានជំទាស់នឹងឯកសារណាមួយ និងរាល់ឯកសារទាំងអស់ដែលនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា "ដែលមិនមានការទាក់ទងដោយផ្ទាល់" ទៅនឹងជនជាប់ចោទណាម្នាក់ក្នុងចំណោមជនជាប់ចោទដែលអាចនឹងធ្វើសក្ខីកម្ម ឬទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីនានាដែលត្រូវបានកំណត់កាលវិភាគ ដើម្បីចូលមកបង្ហាញខ្លួន នៅក្នុងសវនាការជំនុំជម្រះក្តីលើកដំបូង[23]។ ជនជាប់ចោទទាំងនេះមិនបានផ្តល់មូលដ្ឋានណាមួយជាក់លាក់ ដោយយោងទៅលើវិធានផ្ទៃក្នុង ឬក៏អ្វីផ្សេងពីនេះទៀតទេ សម្រាប់ការជំទាស់ជាលក្ខណៈទូទៅ នេះដែលគ្របដណ្តប់ទៅលើរាល់ឯកសារទាំងអស់របស់សហព្រះរាជអាជ្ញានោះឡើយ។ ការសន្និដ្ឋានជាដើមអាទិ៍ដែលស្ថិត

[22] ក្រុមមេធាវីការពារក្តីរបស់ អៀង សារី , ខៀវ សំផន, និងអៀង ធីរិទ្ធ ក្រុមនីមួយៗបានដាក់បញ្ជីឯកសារនៅថ្ងៃទី១ វិច្ឆិកា ២០១១។ បទចោទប្រកាន់ប្រឆាំងនឹង អៀង ធីរិទ្ធ ក្រោយមកទៀតត្រូវបានបំបែកចេញពីសំណុំរឿងលេខ០០២។

[23] អញ្ញត្រកម្មរបស់ អៀង សារី, កំណត់សម្គាល់លេខ១២ *ខាងដើម* ត្រង់ទំព័រ១។ ឯកសារលេខ E131/6 អញ្ញត្រកម្មរបស់ ខៀវ សំផន កំណត់សម្គាល់លេខ១៥ *ខាងដើម* ត្រង់កថាខណ្ឌទី១៧។

នៅពីក្រោយការជំទាស់នេះ គឺគ្រាន់តែអាចថាបានតែប៉ុណ្ណោះថា មានលក្ខខណ្ឌតម្រូវឱ្យឯកសារ ឬភស្តុតាងទាំងឡាយដែលសហព្រះរាជអាជ្ញាខំទាមទាររកសុំឱ្យទទួលយកត្រូវតែមានការ "ជាប់ទាក់ទងដោយផ្ទាល់" ជាមួយនឹងបុគ្គលទាំងឡាយដែលអាចនឹងធ្វើសក្ខីកម្មនៅក្នុងអម្លុងពេលនៃសវនាការជំនុំជម្រះក្តីលើកដំបូង ។ គ្មានមូលដ្ឋានណាសម្រាប់ឱ្យសន្និដ្ឋាននេះឡើយ។

១៨- ការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង បាននិយាយអំពីឯកសារនានាដែលត្រូវទទួលយក "ដែលជាប់ទាក់ទង"ទៅនឹងជនទាំងឡាយដែលអាចនឹងត្រូវបានកោះហៅឱ្យចូលមកធ្វើសក្ខីកម្ម[24]។ គ្មានលក្ខខណ្ឌតម្រូវចំពោះឯកសារដែលបានស្នើឡើងដែលតម្រូវឱ្យ "ទាក់ទងដោយផ្ទាល់" ទៅនឹងសាក្សីដែលមានសក្តានុពលនោះឡើយ។ ហើយក៏គ្មានលក្ខខណ្ឌតម្រូវបែបនេះផងដែរនៅក្នុងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង ដែលចែងអំពីលក្ខណៈវិនិច្ឆ័យដែលផ្អែកតាមលក្ខណៈវិនិច្ឆ័យនោះ អង្គជំនុំជម្រះសាលាដំបូងអាចនឹងបដិសេធលើភស្តុតាង។ ដោយមេធាវីការពារក្តីខកខានមិនបានផ្តល់ការណែនាំណាមួយអំពីថា តើពាក្យ"ទាក់ទងដោយផ្ទាល់" មានន័យថាដូចម្តេចពិតប្រាកដ? អង្គជំនុំជម្រះមិនអាចពិនិត្យពិចារណាឱ្យប្រកបទៅដោយអត្ថន័យ ឬយកការជំទាស់ជាលក្ខណៈទូទៅនេះ មកអនុវត្តបានទេ។ អាស្រ័យហេតុនេះ ការជំទាស់ទាំងនេះមិនគ្រាន់តែគ្មានមូលដ្ឋានតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងមិនអាចចាត់វិធានការអ្វីកើតលើការជំទាស់ទាំងនេះទៀតផង។

១៩- ជាបន្ថែមពីលើនេះ គេបានកត់សំគាល់ឃើញថា អៀង សារី និង ខៀវ សំផន មិនបានខិតខំប្រឹងប្រែងសូម្បីតែជាអប្បរមាក៏គ្មានដែរ ដើម្បីដកចេញពីក្នុងការជំទាស់ជាលក្ខណៈទូទៅនេះនូវឯកសារទាំងឡាយដែលមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារ របស់ពួកគេផងដែរ[25]។ មានឯកសារចំនួន២០នៅក្នុងបញ្ជីឯកសាររបស់ អៀង សារី[26] ដែល

---

[24] ឯកសារលេខ **E131/1** អនុស្សរណៈ, កំណត់សម្គាល់លេខ៨ *ខាងដើម* ត្រង់ទំព័រ១។

[25] ឯកសារលេខ **E131/1/3** បញ្ជីឯកសាររបស់ អៀង សារី សម្រាប់វគ្គនៃសវនាការជំនុំជម្រះក្តីលើកដំបូង, ចុះថ្ងៃទី១ វិច្ឆិកា ២០១១ ("បញ្ជីឯកសាររបស់ អៀង សារី")។ ឯកសារលេខ **E131/1/6** សញ្ញាបង្ហាញទាក់ទងនឹងសាក្សី និងឯកសារនានាសម្រាប់ដំណាក់កាលទី១នៃសវនាការលើកដំបូង ។ ថ្ងៃទី២ វិច្ឆិកា ២០១១ និងឯកសារភ្ជាប់ជាមួយលេខ E131/1/6.1 ("បញ្ជីឯកសាររបស់ ខៀវ សំផន")។

[26] លេខយោងសំណុំរឿងនៃឯកសារទាំងនេះ និងលេខរៀងដែលក្នុងនោះគេឃើញមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញានោះគឺ: ឯកសារលេខ D22/42 (ឯកសារ 86)។ ឯកសារលេខ D22/42.3 (ឯកសារ 86)។ ឯកសារលេខ D208/2 (ឯកសារ 633)។ ឯកសារលេខ D22/43 (ឯកសារ 85)។ ឯកសារលេខ D22/43.2។ (ឯកសារ 85)។ ឯកសារលេខ D208/3(ឯកសារ 956)។ ឯកសារលេខ D232/59។ (ឯកសារ 970)។ ឯកសារលេខ D22/3605 (ឯកសារ 87)។ ឯកសារលេខ D232/59.1 (ឯកសារ 971)។ ឯកសារលេខ D91/3 (929)។ ឯកសារលេខ D279/6។ (ឯកសារ 974)។ ឯកសារលេខ D279/7(ឯកសារ 975)។ ឯកសារលេខ D279/7.4 (ឯកសារ 345)។ ឯកសារលេខ

មានផងដែរនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និងឯកសារចំនួន៥២ ក្នុងបញ្ជីឯកសាររបស់ ខៀវ សំផន[27] ដែលនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាក៏ឃើញមានដូចគ្នាដែរ។ តាមការសន្និដ្ឋាន អៀង សារី និង ខៀវ សំផន ចាត់ទុកថាឯកសារទាំងនេះថាមានការ"ទាក់ទងដោយផ្ទាល់" ទៅនឹងសក្ខីកម្មរបស់សាក្សីដែលហេតុដូចនេះគួរតែត្រូវបានដកឯកសារទាំងនេះចេញពីការជំទាស់មានលក្ខណៈទូទៅរបស់ពួកគេ។ ការខកខានរបស់ពួកគេក្នុងការធ្វើដូច្នេះ គឺជាការបង្ហាញឲ្យឃើញអំពីលក្ខណៈនៃការពិចារណាខុសនៃការជំទាស់ និងការខកខានរបស់មេធាវីការពារក្តីមិនបានប្រើអស់វីរិយភាព ក្នុងការឆ្លើយតបទៅនឹងការណែនាំរបស់អង្គជំនុំជម្រះ។

២០- សហព្រះរាជអាជ្ញាសូមលើកឡើងថា ឯកសារដែលនៅក្នុងបញ្ជីឯកសាររបស់ពួកគាត់មានការជាប់ទាក់ទងគ្រាប់គ្រាន់ជាមួយដើម្បណ្តឹងរដ្ឋប្បវេណីនិងសាក្សីនានា ដែលត្រូវបានដាក់នៅក្នុងកាលវិភាគ

---

D234/4 (ឯកសារ 957)។ ឯកសារលេខ D234/8 (ឯកសារ 960)។ ឯកសារលេខ D234/15 (ឯកសារ 972)។ ឯកសារលេខ D234/16 (ឯកសារ 973)។ ឯកសារលេខ D166/166។ (ឯកសារ 950)។ កំណត់ហេតុធ្វើសម្ភាសន៍ឈ្មោះ រចឹម ទុន (ហៅ ភី ភួន) Rochoem Ton (alias Phy Phuon) ចុះថ្ងៃទី១៩ ធ្នូ ២០១០ ( ឯកសារ 928)។

[27] លេខយោងសំណុំរឿងនៃឯកសារទាំងនេះ, និងលេខរៀងដែលក្នុងនោះគេឃើញមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញានោះគឺ:: ឯកសារលេខ D161/1.30, D279/6.5 (ឯកសារ 180)។ ឯកសារលេខ D269/9/1.16 (ឯកសារ 103)។ ឯកសារលេខ D279/6.1 (ឯកសារ 544)។ ឯកសារលេខ D279/7.2 (ឯកសារ 544)។ ឯកសារលេខ D279/7.1 (ឯកសារ 558)។ ឯកសារលេខ D262.27 (ឯកសារ 363)។ D175/3.17 (ឯកសារ 409)។ ឯកសារលេខ D175/3.77 (ឯកសារ 687)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ 21.74 (ឯកសារ 457)។ ឯកសារលេខ D279/6.6 (ឯកសារ 246)។ ឯកសារលេខ D279/6.7 (ឯកសារ 257)។ ឯកសារលេខ D279/6.13 (ឯកសារ 263)។ ឯកសារលេខ D279/6.8 (ឯកសារ 272)។ ឯកសារលេខ D279/6.9 (ឯកសារ 276)។ ឯកសារលេខ D248/3.3 (ឯកសារ 162)។ ឯកសារលេខ D279/7.5 (ឯកសារ 295)។ ឯកសារលេខ D279/6.10 (ឯកសារ 305)។ ឯកសារលេខ D279/7.7 (ឯកសារ 323)។ ឯកសារលេខ D279/6.12 (ឯកសារ 325)។ ឯកសារលេខ D279/6.4 (ឯកសារ 332)។ ឯកសារលេខ D279/6.2 (ឯកសារ 334)។ ឯកសារលេខ D279/6.3 (ឯកសារ 341)។ ឯកសារលេខ D279/7.10 (ឯកសារ 569)។ ឯកសារលេខ D279/7.4 (ឯកសារ 345)។ ឯកសារលេខ D279/7.9 (ឯកសារ 347)។ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ 3.1, ឯកសារលេខ D279/7.8 (ឯកសារ 178)។ IS 20.3 (ឯកសារ 919)។ ឯកសារលេខ D366/7.1.584 (ឯកសារ 917)។ ឯកសារលេខ D222/1.15 (ឯកសារ 82)។ ឯកសារលេខ D91/3 (ឯកសារ 929)។ ឯកសារលេខ D91/10 (ឯកសារ 930)។ ឯកសារលេខ D91/21 (ឯកសារ 932)។ ឯកសារលេខ D22/43 (ឯកសារ 85)។ ឯកសារ D89 (ឯកសារលេខ 938)។ ឯកសារលេខ D22/42 (ឯកសារលេខ 86)។ ឯកសារលេខ D107/3 (ឯកសារ 940)។ ឯកសារលេខ D125/160 (ឯកសារលេខ 941)។ ឯកសារលេខ D200/3 (ឯកសារលេខ 942)។ ឯកសារលេខ D143 (ឯកសារ 945)។ ឯកសារលេខ D166/166 (ឯកសារ 950)។ ឯកសារលេខ D199/20 (ឯកសារលេខ 952)។ D208/3 (ឯកសារលេខ 956)។ ឯកសារលេខ D234/4 (ឯកសារ 957)។ ឯកសារលេខ D234/8 (ឯកសារលេខ 960)។ ឯកសារលេខ D208/2 (ឯកសារ 633) ឯកសារលេខ D247/1 (ឯកសារលេខ 969)។ ឯកសារលេខ D232/59 (ឯកសារ 970)។ ឯកសារលេខ D234/15 (ឯកសារលេខ 972)។ ឯកសារលេខ D234/16 (ឯកសារលេខ 973)។ ឯកសារលេខ D279/6 (ឯកសារលេខ 974)។ ឯកសារលេខ D279/7 (ឯកសារលេខ 975)។ ឯកសារលេខ D369/36 (ឯកសារលេខ 978)។

ដើម្បីឱ្យផ្តល់សក្ខីកម្មនៅក្នុងសវនាការជំនុំជម្រះក្តីលើកដំបូង[28]។ សាក្សីដែលត្រូវបានដាក់ក្នុងកាលវិភាគបានដឹងអំពីទិដ្ឋភាពផ្សេងៗនៃរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ អំពីតួនាទីរបស់ជនជាប់ចោទ និងអំពីគោលនយោបាយនានារបស់ បកក និងកម្ពុជាប្រជាធិបតេយ្យ។ សហព្រះរាជអាជ្ញាមានសិទ្ធិក្នុងការដាក់សម្រាប់សាក្សីទាំងនេះនូវឯកសារនានា ទាក់ទងនឹងប្រធានបទដំណាក់កាលទី១ដែលមានហេតុផលជឿជាក់ថានៅក្នុងរង្វង់នៃការដឹងរបស់ពួកគេ និងអំពីប្រធានបទនេះ ពួកគេមានសមត្ថភាពអាចផ្តល់សក្ខីកម្មបានទោះបីជាឯកសារទាំងនោះមុនមិនត្រូវបាននិពន្ធ ឬផ្សព្វផ្សាយក៏ដោយ ឬមួយក៏សាក្សីទាំងនោះមិនធ្លាប់បានឃើញមិនពីមុនមក។ លើសពីនេះ អង្គជំនុំជម្រះថ្មីៗនេះបានបញ្ជាក់[29] ក្នុងការឆ្លើយតបទៅនឹងសំណើមួយរបស់សហព្រះរាជអាជ្ញា[30] ដែលថាឯកសារទាំងឡាយចាំបាច់ត្រូវតែធ្វើសំណើសុំជាផ្លូវការ តាមរយៈសាក្សីនានានិងអាចដាក់ជូនទៅអង្គជំនុំជម្រះដោយផ្ទាល់។ ដើម្បីជាប្រយោជន៍សមត្ថភាព សហព្រះរាជអាជ្ញាអាចស្វែងរកសុំដើម្បីឱ្យបង្ហាញជូនដោយផ្ទាល់ទៅអង្គជំនុំជម្រះនូវឯកសារនានា ដែលមកពីក្នុងបញ្ជីឯកសាររបស់ខ្លួនដែលជាប្រភេទស្រដៀងគ្នា ឬមានប្រភេទដូច ទៅនឹងឯកសារផ្សេងទៀត ដែលបានដាក់សម្រាប់សាក្សីណាម្នាក់ វាប្រសើរជាជាងការដាក់ឯកសារនីមួយៗតាមរយៈសាក្សីម្នាក់។ ចុងក្រោយនេះគ្រាន់តែមិនអាចឈានទៅដល់ទំហំ និងភាពស្មុគស្មាញនៃរឿងក្តី។

### *ii. ចម្លើយដែលបានមកតាមរយៈការធ្វើទារុណកម្ម*

២១- ខៀវ សំផន នៅរក្សាជំហរដែលថា ឯកសារណាមួយចំនួនដែលនៅក្នុងនោះមានចម្លើយនានា ដែលបានមកដោយសារការធ្វើទារុណកម្ម គឺមិនអាចឱ្យទទួលយកបានដើម្បីប្រឆាំងនឹងជនជាប់ចោទនោះឡើយ ហើយស្នើសុំឱ្យអង្គជំនុំជម្រះបដិសេធចោលរាល់ "ចម្លើយទាំងអស់ដែលបានមកដោយសារ

[28] ដូចបានបញ្ជាក់ខាងលើ សហព្រះរាជអាជ្ញារក្សាសិទ្ធិក្នុងការប្រើប្រាស់ឯកសារដទៃទៀត ពីក្នុងបញ្ជីឯកសារដំណាក់កាលដំបូងរបស់ខ្លួន និងដែលឯកសារនោះទាក់ទងនឹងទិដ្ឋភាពប្រវត្តិសាស្ត្រ ជាប់ពាក់ព័ន្ធជាមួយជនជាប់ចោទ ដែលអាចឆ្លើយ។

[29] ឯកសារលេខ **E141** អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៧ វិច្ឆិកា ២០១១ ត្រង់ទំព័រ៥។

[30] ឯកសារលេខ **E136** សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យបង្កើតប្រព័ន្ធដ៏មានប្រសិទ្ធភាពមួយសម្រាប់ការទទួលយកភ័ស្តុតាងជាឯកសារនៅក្នុងសវនាការ, ចុះថ្ងៃទី៣ វិច្ឆិកា ២០១១។

ការធ្វើទារុណកម្ម"[31]។ នៅក្នុងការជំទាស់ពីមុនៗ អៀង សារី បានជំទាស់ទៅនឹងការប្រភេទទូលំទូលាយជាងនៃឯកសារនានា "ដែលបានមកដោយសារការធ្វើទារុណកម្ម"[32]។

២២- នៅក្នុងការចាប់ផ្តើមដំបូងនៃកំណត់សំគាល់របស់សហព្រះរាជអាជ្ញា ដែលវិធានស្តីពីការដកចេញដែលមានចែងក្នុងមាត្រា១៥ នៃអនុសញ្ញារបស់ អ.ស.ប ស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ("CAT") គឺទាក់ទងតែទៅនឹងចម្លើយទាំងឡាយណា "ដែលបានបង្ហាញភស្តុតាងឱ្យឃើញថាបានធ្វើឡើងនៅក្រោមការធ្វើទារុណកម្ម" តែប៉ុណ្ណោះ។ អនុសញ្ញានេះក៏អនុញ្ញាតផងដែរនូវការប្រើប្រាស់នូវចម្លើយបែបនេះ "ប្រឆាំងនឹងជនណាម្នាក់ដែលត្រូវបានចោទប្រកាន់អំពីការធ្វើទារុណកម្មដើម្បីជាភស្តុតាងអំពីចម្លើយនោះត្រូវបានធ្វើឡើង"[33]។ ដើម្បីឱ្យការហាមឃាត់ត្រូវបានគេយកមកអនុវត្តនោះ ចម្លើយខ្លួនឯងផ្ទាល់នោះ ទីមួយត្រូវតែបង្ហាញឱ្យឃើញថាទទួលបានមកនៅក្រោមការធ្វើទារុណកម្ម និងទីពីរការប្រើចម្លើយនេះ ត្រូវតែមានការហាមឃាត់ដោយអនុសញ្ញានេះ។ អាស្រ័យហេតុនេះ សំខាន់គឺត្រូវញែកឱ្យដាច់គ្នារវាងប្រភេទផ្សេងៗនៃភស្តុតាងជាសម្ភារៈ ដែលបានរកឃើញនៅក្នុងសំណុំឯកសាររបស់មន្ទីរសន្តិសុខនានា (ដែលត្រូវបានគេអធិប្បាយយ៉ាងសាមញ្ញថាជា "ចម្លើយសារភាព") និងរវាងការប្រើប្រាស់ផ្សេងៗដែលប្រភេទឯកសារទាំងនេះត្រូវបានគេដាក់បញ្ចូលជាភស្តុតាង។

២៣- ជាបន្ថែមពីលើចម្លើយសារភាពនានាដែលបានចុះហត្ថលេខាដោយជនជាប់ឃុំឃាំង សំណុំឯកសារនៃចម្លើយសារភាពដែលនៅក្នុងសំណុំរឿងជាទូទៅរួមមានសេចក្តីសង្ខេប និងរបាយការនានាដែលបានធ្វើឡើងដោយពួកអ្នកសួរចម្លើយដែលកត់ត្រាអំពីអត្តសញ្ញាណរបស់អ្នកទោស ទីកន្លែងនិងកាលបរិច្ឆេទនៃការចាប់ខ្លួន និងការរៀបរាប់អំពីប្រភេទនៃការបង្ខិតបង្ខំ ឬការធ្វើទារុណកម្មដែលបានប្រើប្រឆាំងនឹងអ្នកទោស។ ដោយសារតែចម្លើយទាំងនេះត្រូវបានកត់ត្រាដោយតតីយភាគីនានា

---

[31] ឯកសារលេខ **E131/6** ការជំទាស់របស់ ខៀវ សំផន, កំណត់សម្គាល់លេខ១៥ *ខាងដើម* ត្រង់កថាខណ្ឌទី១៨-២០។

[32] ឯកសារលេខ **E114** ការជំទាស់ពីមុនៗរបស់ អៀង សារី, កំណត់សម្គាល់លេខ១២ *ខាងដើម* ត្រង់កថាខណ្ឌទី១៧ ដែលដាក់បញ្ចូលដោយយោងលើឯកសារលេខ **E33** ញត្តិរបស់ អៀង សារី
ប្រឆាំងនឹងការប្រើប្រាស់នូវភ័ស្តុតាងដែលបានមកដោយសារការធ្វើទារុណកម្មនៅក្នុងសវនាការ, ចុះថ្ងៃទី៤ កុម្ភៈ ២០១១។ សូមអានផងដែរ ឯកសារលេខ **E114/1** ចម្លើយតបទៅនឹងការជំទាស់ពីមុនៗរបស់ អៀង សារី, កំណត់សម្គាល់លេខ១៤ *ខាងដើម* ត្រង់កថាខណ្ឌទី៣៩-៤១។

[33] អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម នឹងប្រព្រឹត្តិកម្មដែលសាហាវព្រៃផ្សៃអមនុស្សធម៌ ឬបន្ទាបបន្ថោក និងការផ្តន្ទាទោស, សេចក្តីសំរេចិត្តរបស់មហាសន្និបាត អ.ស.ប លេខ G.A. Res 39/46, U.N. GAOR, 39th Sess., Supp. No. 51, ឯកសារ អ.ស.ប លេខ Doc. A39/51 (ឆ្នាំ១៩៨៤), មាត្រា១៥ (" នៃអនុសញ្ញា CAT")។

(ដែលមិនដាក់ឲ្យទទួលរងទារុណកម្មទេ) និងដែលមិនផ្អែកលើមូលដ្ឋាននៃព័ត៌មានដែលបានមកពីអ្នកទោសដែលស្ថិតក្រោមការធ្វើទារុណកម្មនោះ គឺចម្លើយទាំងនេះមិនស្ថិតនៅក្រោមវិធានស្តីពីការដកចេញនោះឡើយ។ ចម្លើយទាំងនវអាចត្រូវបានគរប្រើសម្រាប់បង្ហាញសក្ខីកម្មអំពីអត្តសញ្ញាណរបស់ជនដែលត្រូវគេចាប់ខ្លួន, ឃុំខ្លួន, និងធ្វើទារុណកម្ម ហើយនិង ការរៀបរាប់ដោយលំអិតអំពីការចាប់ខ្លួន និងការធ្វើទារុណកម្ម។ សេចក្តីសង្ខេប និងរបាយការណ៍នានា ជាញឹកញយតែងតែរួមបញ្ចូលនូវបញ្ជីកម្មាភិបាលនានា និងជនដទៃៗទៀតដែលត្រូវបានជនជាប់ឃុំឃាំងឆ្លើយដាក់។ បញ្ជីទាំងនេះអាចត្រូវបានគេយកមកប្រើដើម្បីបង្ហាញឲ្យឃើញអំពីផែនការឧក្រិដ្ឋកម្មរួមនៃការរកឲ្យឃើញអត្តសញ្ញាណ និងការលប់បំបាត់ចោលនូវពួកអ្នកដែលប្រឆាំងនឹងរបប តាមរយៈការប្រើប្រាស់នូវការធ្វើទារុណកម្មជាលក្ខណៈប្រព័ន្ធ។

២៤- ចម្លើយសារភាពមួយចំនួនក្នុងសំណុំរឿង រួមមានលិខិតដែលបានផ្ញើដោយពួកអ្នកទោសខ្លួនឯងទៅជូនពួកមេដឹកនាំនានាដែលក្នុងនោះរួមទាំងជនជាប់ចោទផង ដែលអង្វរសុំដើម្បីឲ្យដឹកនាំទាំងនោះជួយស្រោចស្រង់ជីវិតពួកគេ។ប្រភេទនៃឯកសារទាំងនេះអាចនឹងត្រូវបានយកទៅប្រើធ្វើជាភ័ស្តុតាងអំពីតំណែងជាន់ខ្ពស់ ឬអំពីសិទ្ធិអំណាចរបស់ជនជាប់ចោទ។

២៥- សំណុំឯកសារនៃចម្លើយសារភាពភាគច្រើនក៏មានរួមបញ្ចូលក្នុងនោះផងដែរនូវចំណារនានាដែលធ្វើឡើងដោយតតីយជន ដែលក្នុងនោះរួមមានជនចាប់ចោទផង ដែលបានទទួលនិងពិនិត្យមើលឡើងវិញលើចម្លើយសារភាព។ ចំណារទាំងនេះអាចឲ្យយកមកពឹងផ្អែកធ្វើជាភ័ស្តុតាងដែលទទួលបានពីក្នុងចំណោមចម្លើយសារភាពដោយជនជាប់ចោទ អំពីការចូលរួមនៅក្នុងវិធីដំណើរការក្នុងការធ្វើសេចក្តីសម្រេចនានាដែលទាក់ទងទៅនឹងការចាប់ខ្លួនជាបន្ថែមទៀត និងអំពីការដឹងអំពីការចាប់ខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់អ្នកទោសដោយខុសច្បាប់។

២៦- ជាចុងក្រោយ ព័ត៌មានដែលមាននៅក្នុងឯកសារចម្លើយសារភាពផ្ទាល់អាចត្រូវបានយកមកប្រើដើម្បីបង្ហាញសក្ខីកម្មអំពីអង្គហេតុជាក់ស្តែងដែលថា ការធ្វើទារុណកម្មបានកើតមាន ដែលរួមទាំងអត្តសញ្ញាណរបស់អ្នកទោស កាលបរិច្ឆេទនៃការចាប់ខ្លួននឹងឃុំខ្លួន វិធីសាស្ត្រនៃការធ្វើទារុណកម្ម និងកម្មវត្ថុរឿងដែលជនជាប់ឃុំឃាំងត្រូវបានគេសួរចម្លើយ។ រួមគ្នាជាមួយនឹងឯកសារដទៃៗទៀត ចម្លើយសារភាពទាំងនេះក៏អាចបង្ហាញផងដែរថាព័ត៌មានដែលបានមកពីជនជាប់ឃុំឃាំងត្រូវបានគេ

យកទៅប្រើធ្វើជាមូលដ្ឋានសម្រាប់ការចាប់ខ្លួននិងការបោសសំអាតនាពេលអនាគត។ មិនមានការលើកឡើងអនុសាសន៍ថា ព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពមួយគួរត្រូវបានពឹងផ្អែកលើដោយសហព្រះរាជអាជ្ញា ដើម្បីបង្ហាញភ័ស្តុតាងឲ្យឃើញអំពីការពិតដែលមាន នៅក្នុងខ្លឹមសារនៃចម្លើយសារភាពនោះឡើយ(ឧទាហរណ៍ថា អ្នកទោសឬជនណាម្នាក់ដែលត្រូវ បានគាត់ដាក់ ឈ្មោះថាជា "គេញ" ឬជា "ខ្មាំង") ឬតាមវិធីផ្សេងៗជាច្រើនដែលឈានហួសពីបទដ្ឋានដែលបានចែងកំណត់ ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿងលេខ០០១។ នៅក្នុងសំណុំរឿងលេខ០០១ អង្គជំនុំជម្រះសាលាដំបូង បានទទួលយកនូវឯកសារចម្លើយនៃសារភាពនៅមន្ទីរស-២១មួយចំនួនដែលកត់សំគាល់ថាឯកសារទាំងនេះ "មិនត្រូវបានទទួលយកសម្រាប់ការពិតដែលមាន នៅក្នុងខ្លឹមសាររបស់ចម្លើយសារភាពនោះទេ" ប៉ុន្តែប្រសើរជាងនេះ ក្នុងនាមជាភ័ស្តុតាងអំពីអង្គហេតុដែល "ចម្លើយសារភាពត្រូវបានធ្វើឡើង" ហើយបើសិនជាឲ្យសមស្របនោះគឺ "ចម្លើយសារភាពដែលត្រូវបានធ្វើឡើងក្រោមការធ្វើទារុណកម្ម"[34]។

២៧- ដើម្បីឲ្យឯកសារជាពិសេសណាមួយដែលនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ត្រូវបានយល់ឃើញថា មិនអាចទទួលយកបាន តាមស្មារតីនៃមាត្រា១៥នៃអនុសញ្ញា CAT នោះ តែងតែបង្ហាញឲ្យឃើញថា នៅក្នុងឯកសារនោះមានចម្លើយនានាដែលបានមកដោយសារការធ្វើទារុណកម្ម និងឲ្យឃើញថាសំណើសុំប្រើប្រាស់នូវចម្លើយនោះគឺមិនស្ថិតនៅក្នុងវង្វង់នៃការលើកលែង ដែលត្រូវបានគេទទួលស្គាល់ឡើយ។ ការជំទាស់ដែលមានលក្ខណៈទូទៅ ដែលបានដាក់ជូនដោយ ខៀវ សំផន និង អៀង សារី ខកខានមិនបានធ្វើឲ្យសម្រេច ឬដែលមិនបានខិតខំព្យាយាម ដើម្បីធ្វើឲ្យសម្រេចតាមបទដ្ឋាននេះ។

២៨- ខៀវ សំផន ក៏បានជំទាស់ផងដែរចំពោះការដាក់បញ្ចូលនូវចម្លើយសារភាពណាមួយ ដោយផ្អែកលើមូលដ្ឋានថា ដីកាបំបែកកិច្ចដំណើរការនីតិវិធី បានដកនូវមណ្ឌលសន្តិសុខនានាចេញពីក្នុងសវនាការជំនុំជម្រះក្តីលើកដំបូង។ គេសំគាល់ឃើញថា វិសាលភាពបច្ចុប្បន្ននៃសវនាការដំបូង នៅតែដាក់បញ្ចូលនូវ "តួនាទីរបស់ជនជាប់ចោទនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ" និង "គោលនយោបាយនានារបស់កម្ពុជាប្រជាធិបតេយ្យ" ដែលទាក់ទងនឹងបញ្ហានានាដែលត្រូវបានចោទនៅក្នុងដីកា

[34] ឯកសារលេខ **E176** សេចក្តីសំរេចលើសំណើរបស់ភាគីនានាដែលសុំឲ្យដាក់ឯកសារខ្លះ នៅចំពោះមុខអងង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(២) នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២៨ តុលា ២០០៩, ត្រង់កថាខណ្ឌទី៨។

បញ្ជូនរឿងទៅជំនុំជម្រះ។ នេះគឺរួមបញ្ចូលទាំង "ការអប់រំកែប្រែពួក "សមាសភាពមិនល្អ" និងការសម្លាប់ "ពួកខ្មាំង""។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអាចទទួលយកចម្លើយសារភាពនានា ជាពិសេសចម្លើយសារភាពទាំងឡាយណាដែលមានចំណារ ឬឯកសារពាក់ព័ន្ធផ្សេងទៀត បើសិនជាចម្លើយសារភាព ឬឯកសារពាក់ព័ន្ធផ្សេងទៀតទាំងនោះមានទំនោរបង្ហាញសក្ខីកម្មអំពីអត្ថិភាពនៃគោលនយោបាយនេះ និងតួនាទីនិងសិទ្ធិអំណាចរបស់ជនជាប់ចោទ។

### *iii. ចម្លើយសាក្សីនានា*

២៩- ខៀវ សំផន បានជំទាស់ចំពោះការទទួលយកនូវចម្លើយសាក្សីនានាដែលមានក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដែលត្រូវបានធ្វើឡើងដោយជនទាំងឡាយដែលមិនអាចមក ដើម្បីឱ្យភាគីបដិបក្ខធ្វើការសួរដេញដោលនៅក្នុងសវនាការបាន[35] អៀង សារី កាលពីមុនក៏បានធ្វើការជំទាស់មួយស្រដៀងនេះដែរ[36]។

៣០- លទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការទទួលយកចម្លើយសាក្សីនានាដែលនឹងមិនបង្ហាញសក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទណាម្នាក់ ត្រូវបានក្លាយទៅជាកម្មវត្ថុនៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញា[37] និងភាគីផ្សេងៗទៀតរួចទៅហើយៗគឺជាបញ្ហាដែលមួយដែលអង្គជំនុំជម្រះមិនទាន់បានធ្វើការសម្រេចនៅឡើយទេ។

៣១- ហេតុនេះ សហព្រះរាជអាជ្ញា នឹងមិនធើចម្លើយតបតបន្ថែមទៀតចំពោះការជំទាស់នេះ ក្រៅពីធ្វើការកត់សំគាល់ថា ទាំងខៀវ សំផន ក្តី ឬទាំង អៀង សារី ក្តីទាំងអស់គ្នាសុទ្ធតែមិនបានធ្វើការខិតខំប្រឹងប្រែងណាមួយ ដើម្បីដកចេញពីក្នុងការជំទាស់របស់ខ្លួនទៅនឹងចម្លើយជាលាយលក្ខណ៍អក្សររបស់ជនទាំងឡាយដែលត្រូវបានគេកំណត់នៅក្នុងកាលវិភាគ ឬស្នើសុំឱ្យចូលមកបង្ហាញខ្លួននៅក្នុងសវនាការឡើយ។ តាមពិត ក្នុងចំណោមឯកសារទាំង៦៧ដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារ

---

[35] ឯកសារលេខ **E131/6** ការជំទាស់របស់ ខៀវ សំផន,កំណត់សម្គាល់លេខ១៥ *ខាងលើ* ត្រង់កថាខណ្ឌទី២២-២៣។

[36] ឯកសារលេខ **E114** ការជំទាស់ពីមុនរបស់ អៀង សារី, កំណត់សម្គាល់លេខ១២ *ខាងលើ* ត្រង់កថាខណ្ឌទី២០។ សូមអានផងដែរ ឯកសារលេខ **E114/1** ចម្លើយតបទៅនឹងការជំទាស់របស់ អៀង សារី ពីមុនៗ, កំណត់សម្គាល់លេខ១៤ *ខាងលើ* ត្រង់កថាខណ្ឌទី៥០-៥១។

[37] ឯកសារលេខ **E96** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ នៃវិធានផ្ទៃក្នុង ទាក់ទងនឹងការទទួលយកនូវចម្លើយសាក្សីជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៥ មិថុនា ២០១១ និងឯកសារលេខ **E96/6** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនានាទាក់ទងនឹងការទទួលយកនូវចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង , ចុះថ្ងៃទី១០ សីហា ២០១១។

របស់សហព្រះរាជអាជ្ញា ដែលត្រូវបានកំណត់លក្ខណៈសម្បត្តិថាជាចម្លើយសាក្សី (ដែលក្នុងនោះរួមទាំងពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបី ចម្លើយជាលាយលក្ខណ៍អក្សរពីមុនចំនួនដប់បួន និងកំណត់ហេតុស្តាប់ចម្លើយសាក្សីធ្វើឡើង ដោយការិយាល័យសហចៅក្រមស៊ើបអង្កេតចំនួន៥០ផង) គឺមានចំនួន៤៣ឯកសារ ត្រូវបានធ្វើឡើងដោយសាក្សីឬដើមបណ្តឹងរដ្ឋប្បវេណីនានាដែលមានក្នុងបញ្ជីសំរាប់សវនាការជំនុំជម្រះក្តីលើកដំបូងរបស់អង្គជំនុំជម្រះសាលាដំបូង[38] សម្រាប់សវនាការវគ្គដំបូង[39]។

៣២- ជាពិសេស ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងបី បានធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីដែលបានកំណត់ពេលរួចហើយសម្រាប់ការបង្ហាញខ្លួនក្នុងសវនាការវគ្គដំបូង[40]។ កំណត់ហេតុសាក្សីចំនួនប្រាំមួយ ក្នុងចំណោមកំណត់ហេតុទាំង១៤ ត្រូវបានធ្វើឡើងដោយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលបានកំណត់ពេលរួចហើយ សម្រាប់បង្ហាញខ្លួនក្នុងសវនាការវគ្គដំបូង ឬសវនាការដំណាក់កាលដំបូង[41]។ កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនសាមសិបបួនក្នុងចំណោម៥០ កំណត់ហេតុ ត្រូវបានធ្វើឡើងដោយសាក្សី/ដើមបណ្តឹងរដ្ឋប្បវេណីដែលបានកំណត់ពេល បង្ហាញខ្លួនក្នុងសវនាការ[42]។

---

[38] ឯកសារលេខ **E131/1.2** ឧសម្ព័ន្ធ ខ ការសម្គាត់ ដែលភ្ជាប់ជាមួយនឹងអនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២៥ តុលា ២០១១។

[39] ឯកសារលេខ **E131/1.1** ឧសម្ព័ន្ធ ក ការសម្គាត់ ដែលភ្ជាប់ជាមួយនឹងអនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២៥ តុលា ២០១១។

[40] TCCP 142 ធ្វើពាក្យសុំ D22/3605 (ឯកសារ៨៧); TCCP 123 ធ្វើពាក្យសុំ D22/43 (ឯកសារ៨៥); និង TCCP 185 ធ្វើពាក្យសុំ D22/42(ឯកសារ៨៦) ។

[41] TCCP 142 ធ្វើកំណត់ហេតុនៅត្រង់ឯកសារ 924 ;TCW 564 ធ្វើកំណត់ហេតុនៅត្រង់ឯកសារ 928; TCW-694 ធ្វើកំណត់ហេតុ IS 3.9 (ឯកសារ 916); TCW 321 ធ្វើកំណត់ហេតុ D224.106 (ឯកសារ 923); TCW 395 ធ្វើកំណត់ហេតុ D366/7.1.584 (ឯកសារ 917) ។

[42] កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនប្រាំបានធ្វើឡើងដោយសាក្សី TCW-586: D369/36 (ឯកសារ 978), D233/9 (ឯកសារ 967), D91/15(ឯកសារ 933), D91/14 (ឯកសារ 931), D233/2 (ឯកសារ 958). កំណត់ហេតុចំនួនប្រាំបានធ្វើឡើងដោយសាក្សី TCW-694: កំណត់ហេតុចំនួនប្រាំបានធ្វើឡើងដោយសាក្សី TCW-694: (ឯកសារ លេខ 945), D91/25(ឯកសារ 935), D91/26(ឯកសារ 936), D147(ឯកសារ 947), D144(ឯកសារ 946). កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនបួនបានធ្វើឡើងដោយសាក្សី TCW-542: D234/8(ឯកសារ 960), D234/16(ឯកសារ 973), D234/4 (ឯកសារ 957), D234/15(ឯកសារ 972)។ កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនបីបានធ្វើឡើងដោយ TCW-480: D200/9(ឯកសារ 948), D200/3.8(ឯកសារ 948), D200/3(ឯកសារ 943)។ កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនបីបានធ្វើឡើងដោយ TCW-307: D369/4(ឯកសារ 976), D125/160(ឯកសារ 941), D200/4 (ឯកសារ 944). កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនពីរបានធ្វើឡើងដោយ TCW 564: D107/3 (ឯកសារ 940), D91/10 (ឯកសារ

### *iv. សម្ភារៈមិនកើតឡើងក្នុងពេលដំណាលគ្នា (សៀវភៅ របាយការណ៍វិភាគ ខ្សែភាពយន្ត)*

៣៣- មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងការដាក់ជូននូវ "សម្ភារៈមិនកើតឡើងដំណាលគ្នា" ណាមួយ រួមមានដូចជា សៀវភៅ របាយការណ៍វិភាគ និងខ្សែភាពយន្តឯកសារដែលមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា[43]។ អៀង សារី កាលពីមុនធ្លាប់បានលើកពីការជំទាស់ទូទៅមួយទៅនឹងការប្រើ"របាយការណ៍ អត្ថបទសារព័ត៌មាននិងឯកសារមិនកើតឡើងក្នុងពេលដំណាលគ្នានានា"[44]។

<u>សៀវភៅ</u>

៣៤- ទាក់ទិននឹងសៀវភៅ, ខៀវ សំផន តវ៉ាថា សៀវភៅទាំងនោះមានជាប់ពាក់ព័ន្ធនឹងអនាគតិបុគ្គល ឬអាចថាមានការពឹងផ្អែកទៅលើប្រភពប្រយោល ដែលសៀវភៅទាំងនោះមិនអាចទទួលយកបាន (ឧទាហរណ៍ ដោយសារវាទទួលបានដោយការធ្វើទារុណកម្ម)។ គាត់ខកខានមិនបានលើកយោងករណីយុត្តិសាស្ត្រណាមួយ ទាំងករណីយុត្តិសាស្ត្រកម្ពុជា ឬអន្តរជាតិដើម្បីគាំទ្រចំពោះជំហររបស់ខ្លួនដែលថា សៀវភៅទាំងនោះ តាមប្រភេទរបស់វា មិនអាចទទួលយកបាន ហើយគាត់ក៏មិនបានចង្អុលប្រាប់ថា តើសៀវភៅណាមួយក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញានាំឱ្យមានកង្វល់អំពីអនាគតិ ឬការពឹងផ្អែកលើប្រភពប្រយោលដែលគេមិនអាចទទួលយកបានដូច្នេះដែរ។ ជាការពិត

---

930). កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនពីរបានធ្វើឡើងដោយ TCW-695: D232/9(ឯកសារ 962), D232/8(ឯកសារ 961). កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនពីរបានធ្វើឡើងដោយ TCCP 142: D232/59(ឯកសារ 970), D232/59.1(ឯកសារ 971). កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនពីរបានធ្វើឡើងដោយ TCW-487: D91/21(ឯកសារ 932), D91/22(ឯកសារ 934). កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនពីរបានធ្វើឡើងដោយ TCW 583: D279/6(ឯកសារ 974), D279/7(ឯកសារ 975). កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនមួយបានធ្វើឡើងដោយ TCCP 123:D208/3 (ឯកសារ 956). កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនមួយបានធ្វើឡើងដោយ TCCP 185: D247/1 (ឯកសារ 969). កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនមួយបានធ្វើឡើងដោយ TCW 395: D91/3 (ឯកសារ 929). កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនមួយបានធ្វើឡើងដោយ TCW 297: D166/166 (ឯកសារ 950)។ គូភាគីថ្មីៗនេះត្រូវបានគេជូនដំណឹងថា សាក្សី TCW 297 បានស្លាប់ហើយ (សូមមើល E141/2 អនុស្សរណៈពីអង្គភាព WESU ជូនអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងសាក្សី TCW-297, ៤ វិច្ឆិកា ២០១១)។ សហព្រះរាជអាជ្ញាបានស្នើឱ្យមានការស៊ើបអង្កេតមួយដើម្បីបញ្ជាក់អះអាងអំពីការស្លាប់សាក្សី TCW 297 (សូមអាន E144 សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យស៊ើបអង្កេត, ២៩ វិច្ឆិកា ២០១១) ។

[43] **E131/6** Exceptions D'Irrecevabilité Portant Sur Les Listes de Documents Présentées par les autres parties pour la première session du premier procès, ១៤ វិច្ឆិកា ២០១១, កថាខ័ណ្ឌទី២៥-៣៤ ។

[44] **E114** ការជំទាស់ពីមុនរបស់ អៀង សារី, កំណត់សម្គាល់*ខាងដើម* លេខ១២ ត្រង់កថាខ័ណ្ឌទី១៨-១៩ ។ សូមអានផងដែរ **E114/1** ចម្លើយតបទៅនឹងការជំទាស់ពីមុនរបស់ អៀង សារី, កំណត់សម្គាល់*ខាងដើម* លេខ១៤ ត្រង់កថាខ័ណ្ឌទី៤៦-៤៩ ។

មានសៀវភៅពីរក្បាល ក្នុងចំណោមសៀវភៅដែលមានក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ត្រូវបាននិពន្ធដោយ ខៀវ សំផន[45]។ ចំណែកមួយក្បាលទៀត គឺជាសៀវភៅដែលបានដាក់បញ្ចូលក្នុងបញ្ជីឯកសារដែលបានស្នើឡើងរបស់ ខៀវ សំផន ខ្លួនឯងផ្ទាល់[46] និងចំណែកមួយក្បាលទៀតត្រូវបានលើកយោងដោយមេធាវីការពារក្តីអន្តរជាតិរបស់ ខៀវ សំផន ក្នុងពេលធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់[47]។

៣៥- ច្បាប់ជាធរមាននៅអ.វ.ត.ក មិនដាក់បញ្ចូលសៀវភៅជាប្រភេទមួយនៃភ័ស្តុតាងឡើយ។ ទោះបីយ៉ាងណា សៀវភៅចំនួនបីក្បាលក្នុងចំណោមសៀវភៅទាំងឡាយ ដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ត្រូវបានអង្គជំនុំជម្រះសាលាដំបូងដាក់បញ្ចូលក្នុងសំណុំរឿង០០១[48] បន្ថែមលើសៀវភៅយ៉ាងហោចណាស់ចំនួន១៣ក្បាលទៀត[49]។ អ្នកនិពន្ធសៀវភៅទាំងអស់នេះ មិន

---

[45] IS 4.23 (ឯកសារ 81) **ខៀវ សំផន**, *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗ និងមូលហេតុនៃសេចក្តីសម្រេចចិត្តដែលខ្ញុំបានធ្វើ (Cambodia's Recent History and the Reasons behind the Decisions I Made)*; D213.2 (ឯកសារ 83) **ខៀវ សំផន**, *ការពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា (Considerations on the History of Cambodia).*

[46] IS 4.41 Philip Short, *ប្រវត្តិសាស្ត្រនៃសុបិន្តអាក្រក់ (History of a Nightmare)*។ សូមអានបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ត្រង់ឯកសារ 82; **E131/1/6.2** Listes de documents relatifs aux témoins de trois premières semaines de procès Annexe 1 *bis*, ឯកសារ 19។

[47] IS 4.2 (ឯកសារ 78) François Bizot, *The Gate.* ប្រតិចារឹក, ២៩ វិច្ឆិកា ២០១១, ទំព័រទី៣៩-៤០ ។

[48] IS 4.15 (ឯកសារ 74) សៀវភៅនិពន្ធដោយ Craig Etcheson, *The Rise and Demise of Democratic Kampuchea,* ត្រូវបានទទួលយកជាឯកសារ E3/330; IS 4.1 (ឯកសារ 75) Elizabeth Becker, *នៅពេលដែលសង្គ្រាមរលត់ទៅ: កម្ពុជា និងបដិវត្តខ្មែរក្រហម"*, ត្រូវបានទទួលយកជាឯកសារ E3/510; និង IS 4.2 (ឯកសារ 78) សៀវភៅនិពន្ធដោយ Francois Bizot, *The Gate*, ត្រូវបានទទួលយកជាឯកសារ E3/4។

[49] សៀវភៅនិពន្ធដោយ ហ៊ុយ វណ្ណៈ *កងពលខ្មែរក្រហមលេខ ៧០៣: ពីជ័យជំនះ ទៅការបំផ្លាយខ្លួនឯង*, ត្រូវបានទទួលយកជាឯកសារ E3/391; សៀវភៅនិពន្ធដោយ អៀង ម៉េងទ្រី, *The Chain of Terror: The Khmer Rouge Southwest Zone Security System*, ត្រូវបានទទួលយកជាឯកសារ E3/48; សៀវភៅនិពន្ធដោយ Menry Kamm, *Cambodia: Report from a Stricken Land*', ត្រូវបានទទួលយកជាឯកសារ E3/87; សៀវភៅនិពន្ធដោយ Nayan Chanda *សត្រូវបងប្អូនឯង: សង្គ្រាមបន្ទាប់ពីសង្គ្រាម*, ត្រូវបានទទួលយកជាឯកសារ E3/193, សៀវភៅនិពន្ធដោយ David Chandler, *សំឡេងពីមន្ទីរស-២១៖ ភាពភ័យខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត*, ត្រូវបានទទួលយកជាឯកសារ E3/427; សៀវភៅនិពន្ធដោយ អ៊ី សាឧស្មាន, *Oukoubah: យុត្តិធម៌សម្រាប់ជនជាតិចាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*, ត្រូវបានទទួលយកជាឯកសារ E3/404; សៀវភៅនិពន្ធដោយ Stephen Morris, *Why Vietnam Invaded Cambodia: Political Culture and the Causes of War*, ត្រូវបានទទួលយកជាឯកសារ E3/523; សៀវភៅនិពន្ធដោយ David Chandler *និងអ្នកនិពន្ធផ្សេងទៀត, Pol Pot*

មានវត្តមានក្នុងពេលសាកសួរសាក្សីរបស់ភាគីបដិបក្ខឡើយ។ ទាក់ទិននឹងសៀវភៅរបស់ Nic Dunlop ដែលមានចំណងជើងថាពេជ្ឈឃាតបាត់ខ្លួន *The Lost Executioner* អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ថាពីដំបូង អ្នកនិពន្ធរូបនោះ ត្រូវបានដាក់ចូលក្នុងបញ្ជីសាក្សី ប៉ុន្តែក្រោយមកត្រូវបានដកចេញវិញ។ ទោះបីយ៉ាងណា អង្គជំនុំជម្រះសាលាដំបូង បានទទួលយកសៀវភៅនោះ ដោយហេតុថាសៀវភៅនោះជាប់ពាក់ព័ន្ធនឹងបញ្ហាសវនាការ[50]។

៣៦- ស្រដៀងគ្នានេះដែរ មិនមានការអនុវត្តនៅកម្រិតអន្តរជាតិ ដែលសៀវភៅនានា ត្រូវបានដកចេញ មិនត្រូវបានប្រើជាប្រភេទទូទៅនៃភស្តុតាងឡើយ។ សាលាក្តីព្រហ្មទណ្ឌពិសេសនានា បានទទួលយកសៀវភៅជាភស្តុតាងសាវតារប្រវត្តិសាស្ត្រ ឬសម្រាប់គោលបំណងតាមបរិបទដទៃទៀត ដែលមិនទាក់ទងនឹងអំពើ និងការប្រព្រឹត្តដែលត្រូវបានចោទរបស់ជនជាប់ចោទ[51]។ ក្នុងរឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Bizimungu* និងអ្នកដទៃ (“*Bizimungu*”)[52] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសរវ៉ាន់ដា (ICTR) បានទទួលយកសេចក្តីសម្រង់ពីសៀវភៅរបស់ឧត្តមសេនីយ៍ Romeo Dallaire មានចំណងជើងថា “Shake Hands with the Devil” ដែលបានលើកឡើងអំពីការចូលរួមរបស់ជនជាប់ចោទម្នាក់ក្នុងក្រុមជ្រុលនិយម Hutu។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសេចក្តីសម្រង់នោះ មានភាពជាប់ពាក់ព័ន្ធ និងមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញអំពីភាពអាចជឿបាន ដោយហេតុថាវាជា “ឯកសារចម្លងនៃសៀវភៅបោះពុម្ពផ្សាយដែលត្រូវបានទទួលស្គាល់”[53]។

---

*Plans the Future: Confidential documents from Democratic Kampuchea*, ត្រូវបានទទួលយកជាឯកសារ E3/67; សៀវភៅនិពន្ធដោយ Raoul M. Jennar *Les Cl"s du Cambodge*, ត្រូវបានទទួលយកជាឯកសារ E3/515"; សៀវភៅនិពន្ធដោយ Nic Dunlop, *ពេជ្ឈឃាដបាត់ខ្លួន*។

[50] E176 សេចក្តីសម្រេចលើសំណើរបស់ភាគីនានាសុំដាក់សម្ភារៈមួយចំនួន នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(២) ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ១០។

[51] សូមមើល សៀវភៅនិពន្ធដោយ May & Weirda, *International Criminal Evidence* (2002) ត្រង់ទំព័រ២៥៨; សៀវភៅនិពន្ធដោយ Khan និងអ្នកផ្សេងទៀត, *Principles of Evidence in International Criminal Justice* (2010) ត្រង់ទំព័រ ៤៨៧។

[52] សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Casimir Bizimungu, Justin-Mugenzi, Jerome-Clement Bicamumpaka, Prosper Mugiraneza* សំណុំរឿង ICTR-99-50-T *សេចក្តីសម្រេចលើបណ្តឹងរបស់រដ្ឋអាជ្ញាដើម្បីដាក់សេចក្តីសម្រង់នៃសៀវភៅរបស់ឧត្តមសេនីយ៍ Romeo Dallaire* (អង្គជំនុំជម្រះសាលាដំបូង ICTR) ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨។

[53] ដូចជើងទំព័រខាងលើ កថាខណ្ឌ ១១

អ្នកនិពន្ធមិនមានវត្ត មាននៅពេលសវនាការសម្រាប់ការសាកសួរសាក្សីរបស់ភាគីបដិបក្ខដោយក្រុមមេធាវីការពារក្តីឡើយ។ យ៉ាងណាមិញ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថាការទទួលយកសេចក្តីសម្រង់នោះ នឹងមិនរំលោភបំពានសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ឡើយ ដោយហេតុថាវានឹងមិនត្រូវបានប្រើ "ដើម្បីកំណត់បទចោទប្រកាន់ណាឡើយ" ប៉ុន្តែវាគ្រាន់តែដើម្បីជាជំនួយដល់អង្គជំនុំជម្រះ "ក្នុងការកំណត់អំពីសារៈសំខាន់ ដែលមាននៅក្នុងសេចក្តីសម្រង់ប្រតិចារឹកនៃសក្ខីកម្មដែលគាត់បានផ្តល់នៅក្នុងកិច្ចដំណើរការនីតិវិធី តែប៉ុណ្ណោះ"[54]។

៣៧- គួរកត់សម្គាល់ថា ក្នុងចំណោម សៀវភៅចំនួនប្រាំបួនក្បាលនៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញាដែលនិពន្ធដោយបុគ្គលដែលពុំមែនជាភាគីក្នុងរឿងក្តី អ្នកនិពន្ធនៃសៀវភៅពីរក្បាលនឹងត្រូវបានកោះហៅឱ្យបង្ហាញខ្លួនក្នុងអំឡុងនៃការជំនុំជម្រះលើកដំបូង[55] រីឯអ្នកនិពន្ធសៀវភៅម្នាក់ ទៀតដែលមានឈ្មោះក្នុងបញ្ជីបណ្តោះអាសន្នមុនរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានផ្សព្វផ្សាយឱ្យភាគីដឹងឮនៅសវនាការបឋម[56] និងអ្នកនិពន្ធសៀវភៅទាំងអស់ លើកលែងតែម្នាក់ចេញ ត្រូវបានស្នើសុំធ្វើជាសាក្សីដោយសហព្រះរាជអាជ្ញា[57]។ គួរកត់សម្គាល់បន្ថែមទៀតថា សៀវភៅចំនួនប្រាំក្បាលដែលស្ថិតនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដូចមានបង្ហាញក្នុងជើងទំព័រនៃកថាខណ្ឌក្នុងដីកាដំណោះស្រាយ អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញថា ខ្លួននឹងអាននៅមុនពេលសួរដេញដោលជនជាប់ចោទ។ ស្របតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង នៅពេលដែលកថាខណ្ឌពាក់ព័ន្ធត្រូវបានអានជូនជាសាធារណៈហើយនោះ ដូច្នេះ សៀវភៅទាំងនេះនឹងត្រូវបានពិចារណាថា ត្រូវបានកំណត់យក លើកលែងតែមានដីកាបង្គាប់ផ្ទុយ[58]។

---

54 ដូចជើងទំព័រខាងលើ កថាខណ្ឌ ១៥

55 អេលីហ្សាបែត ប៊េកខ័រ (TCE-80), ប៉ែន យៀនិន (TCE-38)។ សូមមើលឯកសារលេខ **E131/1.1** ឧបសម្ព័ន្ធសម្ងាត់ "ក" ឆ្លើយតបទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១។

56 Philip Short (TCE-65)។ បញ្ជីបណ្តោះអាសន្ននៃអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង (ផ្សព្វផ្សាយនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១)។

57 Jon Swain (P-006) ។ Francois Bizot (P-007) ។ អ៊ុង ចុងហៀង (P-072) ។ Stephen Heder (P-037) ។ Craig Etcheson (P-295)។ តាមតែអ្នកនិពន្ធ Margaret Slocomb មិនត្រូវបានស្នើសុំដោយសហព្រះរាជអាជ្ញា។ *សូមមើល* ឯកសារលេខ E9/4 បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របស់ សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១។

58 *សូមមើល* ឧបសម្ព័ន្ធ "ក" និង កំណត់សម្គាល់ជើងទំព័រ២៩ *ខាងលើ*។

<u>របាយការណ៍វិភាគ</u>

៣៨- ខៀវ សំផន ជំទាស់ទៅនឹងការទទួលយករបាយការណ៍វិភាគ ដែលមិនបានបន្សល់ទុកពីសម័យនោះ លើមូលដ្ឋានថា របាយការណ៍ទាំងនោះពុំពាក់ព័ន្ធ ហើយអាចទទួលយកបាន លុះត្រាតែអ្នកសរសេររបាយការណ៍ទាំងនោះមានវត្តមាននៅពេលជំនុំជម្រះសម្រាប់ការសួរដេញដោល[59]។ មានឯកសារចំនួនប្រាំច្បាប់ ដែលត្រូវបានដាក់ក្នុងចំណាត់ថ្នាក់ជារបាយការណ៍វិភាគ នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា។ ទោះជាយ៉ាងនេះក្តី ឯកសារមួយក្នុងចំណោមទាំងនេះត្រូវបានរៀបចំក្នុងឆ្នាំ ១៩៧៦ ដូច្នេះហើយវាជាឯកសារដែលបានបន្សល់ទុកពីសម័យនោះ[60]។ ហេតុដូច្នេះហើយ គេសន្និដ្ឋានថា ការជំទាស់របស់ ខៀវ សំផន ពុំពន្លាតដល់ឯកសារនេះឡើយ។

៣៩- ខៀវ សំផន លើកឡើងពីរឿងក្តី *Lubanga*[61] នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ជាការគាំទ្រដល់ការជំទាស់របស់ខ្លួន[62] ប៉ុន្តែពុំបង្ហាញអំពីសទិសភាពគ្រប់គ្រាន់ជាមួយនឹងរឿងក្តីនេះ ដើម្បីធ្វើឱ្យការប្រៀបធៀបបែបនេះប្រកបដោយអត្ថន័យ។ *Lubanga* បារម្ភអំពីការទទួលយកធ្វើជាភ័ស្តុតាងនូវរបាយការណ៍ពិស្តារមួយស្តីពីការធ្វើអាជីវកម្មខុសច្បាប់នូវធនធានធម្មជាតិ និងទម្រង់ផ្សេងៗទៀតនៃទ្រព្យសម្បត្តិរបស់សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ។ អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា របាយការណ៍នេះជាការនិយាយច្រំដែលឡើងវិញនូវភ័ស្តុតាងឯកសារមួយទៀត ដែលត្រូវបានទទួលយករួចហើយ ថាមាតិកានៃរបាយការណ៍នេះគឺមានលក្ខណៈចម្រូងចម្រាស និងបើកចំហឱ្យមានការរិះគន់ ហើយថាគ្មានចំណុចណាមួយក្នុងមាតិកានៃរបាយការណ៍នេះពាក់ព័ន្ធផ្ទាល់ទៅនឹងបទចោទនានាប្រឆាំងនឹងជនត្រូវចោទឡើយ[63]។ វាជាការផ្គុំគ្នានៃកត្តាទាំងនេះ និងការពិតដែលថាអ្នកនិពន្ធរូបនេះមិនត្រូវបានកោះហៅធ្វើជាសាក្សីបានឡើយ ដែលអង្គជំនុំជម្រះបានសម្រេចថា

---

59 ឯកសារលេខ **E131/6** ការជំទាស់របស់ ខៀវ សំផន កំណត់សម្គាល់ជើងទំព័រ ១៥ ខាងលើ កថាខណ្ឌ ៣១-៣២។

60 ឯកសារលេខ D84 - ឧបសម្ព័ន្ធ "ក" - ០១ (ឯកសារ ៦៩)។

61 *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Thomas Lubanga Dyilo រឿងក្តីលេខ ICC-01/04-01/06 សេចក្តីសម្រេចលើសំណើសុំ [ទទួលយករបាយការណ៍] (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ) ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៩ ("សេចក្តីសម្រេចលើរឿងក្តី Lubanga")។

62 ឯកសារលេខ **E131/6** ការជំទាស់របស់ ខៀវ សំផន កំណត់សម្គាល់ជើងទំព័រ ១៥ *ខាងលើ* កថាខណ្ឌ៣២។

63 សេចក្តីសម្រេចលើរឿងក្តី *Lubanga*, កថាខណ្ឌ ៣៣។

អានុភាពអន្តរាយនៃភស្តុតាងនេះនឹងមានសារៈសំខាន់ជាងគុណតម្លៃជាភស្តុតាងរបស់វា។ មេធាវីការពារក្តីរបស់ ខៀវ សំផន ខកខានមិនបានបង្ហាញថា កាលៈទេសៈដូចគ្នានេះមានអត្ថិភាព ពាក់ព័ន្ធនឹងរបាយការណ៍វិភាគ ដែលបានដាក់ស្នើដោយសហព្រះរាជអាជ្ញា ដែលថាឯកសារបែបនេះមិនគួរត្រូវបានទទួលយកនោះ។

៤០- ពាក់ព័ន្ធនឹងសៀវភៅ ពុំមានវិធានទូទៅណាមួយនៅអ.វ.ត.ក ឬក្នុងនីតិវិធីអន្តរជាតិ ក្នុងនោះរួមទាំងការទទួលយករបាយការណ៍វិភាគក្នុងនាមជាចំណាត់ថ្នាក់មួយឡើយ។ សៀវភៅនានាអាចត្រូវបានទទួលយក ដោយសារតែសារៈតារប្រវត្តិសាស្ត្រ ឬគោលបំណងបរិបទ។ ពាក់ព័ន្ធនឹងបញ្ហានេះ គួរកត់សម្គាល់ថា មួយ[64] នៃរបាយការណ៍វិភាគ ដែលមិនបានសន្សល់ទុកពីសម័យនោះ នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ត្រូវបានទទួលយកជាភស្តុតាង ក្នុងសំណុំរឿង០០១ បន្ថែមទៅលើឯកសារ១៥ផ្សេងទៀត ដែលអាចត្រូវបានកំណត់ក្នុងចំណាត់ថ្នាក់ជារបាយការណ៍វិភាគ[65]។

<u>ខ្សែភាពយន្តឯកសារ</u>

៤១- ខៀវ សំផន ជំទាស់នឹងការទទួលយកខ្សែភាពយន្តដែលមិនបានបន្សល់ទុកពីសម័យនោះ លើមូលដ្ឋានថា ខ្សែភាពយន្តទាំងនោះ "កាន់តែមិនគួរឱ្យជឿជាក់បានថែមទៀត [បើប្រៀបធៀបទៅនឹងសៀវភៅ ឬរបាយការណ៍វិភាគ] ត្បិតខ្សែភាពយន្តទាំងនោះមានមហិច្ឆតាផ្នែកសិល្បៈភាពយន្ត"[66]។ ជាថ្មី

[64] ឯកសារលេខ D2-15 (ឯកសារ ៧២ : ត្រូវបានទទួលយកជា ឯកសារលេខ E3/32).

[65] ឯកសារលេខ D2-15.31 ត្រូវបានទទួលយកជា ឯកសារលេខ E3/191។ ឯកសារលេខ D108/41 ត្រូវបានទទួលយកជា ឯកសារលេខ E3/511។ ឯកសារលេខ IS 18.69 ត្រូវបានទទួលយកជា ឯកសារលេខ E3/190។ ឯកសារលេខ D108/51/1.5 ត្រូវបានទទួលយកជា ឯកសារលេខ E3/220។ ឯកសារលេខ IS 2.3 ត្រូវបានទទួលយកជា ឯកសារលេខ E3/46។ ឯកសារលេខ IS 2.1 ត្រូវបានទទួលយកជា ឯកសារលេខ E3/45។ ឯកសារលេខ D108/43/14 ត្រូវបានទទួលយកជា ឯកសារលេខ E3/201។ ឯកសារលេខ IS19.101 ត្រូវបានទទួលយកជា ឯកសារលេខ E3/221។ ឯកសារលេខ D2-15.7 ត្រូវបានទទួលយកជា ឯកសារលេខ E3/102។ ឯកសារលេខ IS 18.81 ត្រូវបានទទួលយកជា ឯកសារលេខ E3/366, E3/367។ ឯកសារលេខ D86/12/I/13/2 ត្រូវបានទទួលយកជា ឯកសារលេខ E3/226។ ឯកសារលេខ D108/19/1 ត្រូវបានទទួលយកជា ឯកសារលេខ E3/232, E3/16។ ឯកសារលេខ D66-Annex A ត្រូវបានទទួលយកជា ឯកសារលេខ E3/506។ ឯកសារលេខ D108/28.43 ត្រូវបានទទួលយកជា ឯកសារលេខ E3/521។ ឯកសារលេខ D108/50/1.10 ត្រូវបានទទួលយកជា ឯកសារលេខ E3/520។

[66] ឯកសារលេខ **E131/6** ការជំទាស់របស់ ខៀវ សំផន កំណត់សម្គាល់ជើងទំព័រ ១៥ *ខាងលើ* កថាខណ្ឌ៣៣។

ម្តងទៀត ពុំមានមូលដ្ឋានផ្នែកច្បាប់ គាំទ្រដល់ការអះអាងនេះឡើយ។ តាមពិតទៅ គឺថាគ្មាន "ខ្សែភាពយន្តឯកសារ" ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាឡើយ។ ដូច្នេះ ការជំទាស់នេះធ្វើឡើងដោយច្រឡំ។ ទោះក្នុងករណីណាក៏ដោយ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ខ្សែភាយយន្តឯកសារដែលមាននៅក្នុងសំណុំរឿង និងដែលអាចនឹងត្រូវបង្ហាញនៅដំណាក់កាលក្រោយៗនៃកិច្ចដំណើរការនីតិវិធី ទាំងពីរគឺជាឯកសារដែលមានភវនីយភាព និងពាក់ព័ន្ធ ឲ្យតែឯកសារទាំងនោះមានកំណត់ហេតុធ្វើឡើងដោយជនជាប់ចោទ ដោយសាក្សី ឬដោយអ្នកជំនាញ និងរូបភាពដែលបង្ហាញពីទីកន្លែង និងព្រឹត្តិការណ៍ផ្សេងៗដែលមាននៅក្នុងដីកាដំណោះស្រាយ។

## V. អត្ថបទសារព័ត៌មាន

៤២- ខៀវ សំផន បានបដិសេធចំពោះការទទួលយកអត្ថបទសារព័ត៌មាន ដែលបានរាយការណ៍អំពីសេចក្តីថ្លែងការណ៍មុនៗរបស់ជនជាប់ចោទ ឬរបស់បុគ្គលណាម្នាក់ លើកលែងតែមានខ្សែអាត់ថតសម្លេងភ្ជាប់មកជាមួយផង[67]។ កាលពីមុននេះ អៀង សារី ក៏បានបដិសេធចំពោះការទទួលយកអត្ថបទសារព័ត៌មានទាំងនេះផងដែរ[68]។

៤៣- ក្រៅពីការសម្អាងទៅលើយុត្តិសាស្ត្រអន្តរជាតិ ដែលជាទូទៅមានមកជាមួយនូវអត្ថបទសារព័ត៌មាន ខៀវ សំផន មិនបានចង្អុលបង្ហាញតាមផ្លូវច្បាប់ណាមួយដល់ការបដិសេធរបស់គាត់នោះឡើយ។ មិនមានមូលដ្ឋានគតិយុត្តិណាមួយសម្រាប់ការជំទាស់របស់គាត់ដែលថា ត្រូវតែមានខ្សែអាត់ថតសម្លេងមកជាមួយ ប្រសិនបើអត្ថបទសារព័ត៌មាន ដែលសហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយករាប់បញ្ចូលនូវសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ ឬរបស់បុគ្គលណាម្នាក់ផងនោះ។ លើសពីនេះទៀត គួរឲ្យកត់សម្គាល់ថា ខៀវ សំផន ខ្លួនឯងស្នើសុំឲ្យទទួលយកអត្ថបទសារព័ត៌មានចំនួនបួន (៤) ច្បាប់ ដែលបានដកស្រង់ពាក្យសំដី ឬរៀបរៀងជាឃ្លាប្រយោគឡើងវិញនូវពាក្យសំដីរបស់ជន

---

[67] ឯកសារ **E131/6** ការជំទាស់របស់លោក ខៀវ សំផន កំណត់សម្គាល់ជើងទំព័រ ១៥ នៅត្រង់កថាខណ្ឌ ៣៧។

[68] ឯកសារ **E114** ការជំទាស់មុនៗរបស់លោក អៀង សារី កំណត់សម្គាល់ជើងទំព័រ ១២ នៅត្រង់កថាខណ្ឌ ១៨-១៩។ សូមមើលផងដែរ ឯកសារ **E114/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "ការជំទាស់មុនៗរបស់លោក អៀង សារី កំណត់សម្គាល់ជើងទំព័រ ១៤ នៅត្រង់កថាខណ្ឌ ៤២-៤៩។

ជាប់ចោទ ឬរបស់បុគ្គលដទៃទៀតនោះ[69] ។

៤៤- ដូចដែលសហព្រះរាជអាជ្ញា បានធ្វើការកត់សម្គាល់នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងការជំទាស់មុនៗរបស់ អៀង សារី ចំពោះអត្ថបទសារព័ត៌មាននានា ការអនុវត្តជាក់ស្តែងរបស់ អ.វ.ត.ក គឺដើម្បីទទួលយកអត្ថបទសារព័ត៌មាន ដែលមានការជាប់ពាក់ព័ន្ធ និងភាពអាចឲ្យជឿទុកចិត្តបានក្នុងកម្រិតអប្បរមា[70]។ ការអនុវត្តជាក់ស្តែងនេះ គឺស្របទៅនឹងតុលាការអន្តរជាតិនានា ដែលអត្ថបទសារព័ត៌មានត្រូវបានទទួលយកជាញឹកញាប់ ហើយជាទូទៅ ត្រូវបានចាត់ទុកថាជា ឯកសារភ័ស្តុតាង ជាជាងចាត់ទុកថាជាចម្លើយសាក្សីទៅវិញនោះ (ជាពិសេស ប្រសិនបើវាជាសេចក្តីរាយការណ៍ព័ត៌មានដែលធ្វើឡើងក្នុងពេលដំណាលគ្នា)។ ហេតុដូច្នេះ វាជាកម្មវត្ថុទៅនឹងវិធាននិយ័តកម្មពាក់ព័ន្ធទៅនឹងភ័ស្តុតាងចចាមអារ៉ាម។ នៅក្នុងរឿងក្តីរបស់ *Brđanin* ជារឿងក្តីមួយដែល ខៀវ សំផន បានលើកឡើងនោះ តុលាការ ICTY បានលើកឡើងថា៖

> *អង្គជំនុំជម្រះសាលាដំបូងមិនយល់ស្របថា អត្ថបទសារព័ត៌មានមួយគឺជាចម្លើយរបស់សាក្សីនោះទេ ហើយក៏មិនបានបកស្រាយថា ភ័ស្តុតាងបែបនោះគឺជាចម្លើយរបស់សាក្សីនោះដែរ។ ជាផលវិបាក អង្គជំនុំជម្រះសាលាដំបូងមិនបានចាត់ទុកសេចក្តីរាយការណ៍ព័ត៌មាន ឬអត្ថបទសារព័ត៌មានថាជាចម្លើយរបស់សាក្សីម្តងណានោះឡើយ ប៉ុន្តែ គ្រាន់តែចាត់ទុកថា សេចក្តីរាយការណ៍ព័ត៌មាន ឬអត្ថបទសារព័ត៌មានអាចទទួលយកជាឯកសារភ័ស្តុតាង នៅក្រោមការអនុវត្តនីតិវិធីជាក់ស្តែងរបស់តុលាការនេះ ជាពិសេស ឯកសារដែលពាក់ព័ន្ធទៅនឹងភ័ស្តុតាងចចាមអារ៉ាម ប៉ុន្តែត្រូវមានកម្រិតដូចបានលើកឡើងខាងលើ។ បញ្ហាដូចគ្នា ត្រូវបានអនុវត្តចំពោះអត្ថបទសំណេរដែលមិនមានឈ្មោះអ្នកនិពន្ធមួយចំនួន ដូចជា ការផ្សព្វផ្សាយព័ត៌មានតាម*

[69] អត្ថបទរបស់សារព័ត៌មាន Herald Tribune ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៦ (បញ្ជីឧបសម្ព័ន្ធ ១ នៃឯកសារ **E131/1/6.2** Listes de documents relatifs aux témoins de trois premières semaines de procès)។ ឯកសារ **D366/7.1.283** (បញ្ជីឧបសម្ព័ន្ធ ១ ស្ថិតនៅក្នុងឯកសារលេខ ៥៣)។ ឯកសារ19 ឯកសារ D262.27 (បញ្ជីឧបសម្ព័ន្ធ ១ ស្ថិតនៅក្នុងឯកសារលេខ ៥៤)។

[70] សូមមើលឯកសារ **E114/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "ការជំទាស់របស់ អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារមួយចំនួន" *លេខជើងទំព័រយោង ១៤ ខាងលើ* ត្រង់កថាខណ្ឌ ៤៧ កត់សម្គាល់ថា នៅក្នុងសំណុំរឿង ០០១ មានអត្ថបទសារព័ត៌មានកម្ពុជាប្រជាធិបតេយ្យ" ចំនួន ៨៥ ច្បាប់ និង "អត្ថបទសារព័ត៌អន្តរជាតិ" ចំនួន ១៣៥ ច្បាប់ ដែលត្រូវបានទទួលយកជាភ័ស្តុតាង។

វិទ្យុ និង/ឬ តាមទូរទស្សន៍ ដែលត្រូវបានចោទប្រកាន់នោះ។[71]

៤៥- ក្រោមយុត្តិសាស្ត្រអន្តរជាតិ អត្ថបទសារព័ត៌មានត្រូវបានយកមកពិចារណាក្នុងកម្រិតខ្ពស់ នៅពេលដែលអត្ថបទសារព័ត៌មានទាំងនោះ បំពេញលក្ខណៈវិនិច្ឆ័យដូចខាងក្រោមនេះ៖ អត្ថបទសារព័ត៌មានទាំងនោះអាចឱ្យជឿជាក់បាន កើតឡើងនៅពេលដំណាលគ្នា ស៊ីសង្វាក់គ្នាជាមួយភស្តុតាងដទៃទៀត និងសំដៅទៅលើចរិតទូទៅនៃព្រឹត្តិការណ៍នានា ឬសារតាប្រវត្តិសាស្ត្រ ឬបង្ហាញថា អង្គហេតុនានាស្ថិតនៅក្នុងការគ្រប់គ្រងជាសាធារណៈ គួរឱ្យជឿជាក់បាន និងមានលក្ខណៈពិត។ ការខកខានមិនបានបំពេញលក្ខណៈវិនិច្ឆ័យទាំងនេះ គឺមិនអាចឱ្យទទួលយកបានឡើយ។ ប៉ុន្តែ វាអាចក្លាយជាកត្តានានា ដែលអាចត្រូវបានយកមកពិចារណា នៅពេលថ្លឹងថ្លែងទៅលើតម្លៃភរនីយហេតុនៃភស្តុតាង។

៤៦- ភាគច្រើននៃសេចក្ដីរាយការណ៍ព័ត៌មាន ដែលបានដាក់បញ្ចូលទៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ត្រូវបានស្នើសុំឱ្យទទួលយក ក្នុងគោលបំណងដើម្បីផ្ដល់បរិបទពាក់ព័ន្ធ ស៊ីសង្វាក់គ្នា និងបញ្ជាក់ពីការដឹងឮរបស់ជនជាប់ចោទអំពីព្រឹត្តិការណ៍ដែលពាក់ព័ន្ធ នៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ។ ភាគច្រើននៃសេចក្ដីរាយការណ៍ព័ត៌មានដែលបានដាក់បញ្ចូលគឺជាអត្ថបទសារព័ត៌មានសហកាល ដែលបានចេញផ្សាយនៅក្នុងអំឡុងពេល ឬភ្លាមៗមុន ឬក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងនៅពេលនោះ។ ដូច្នេះ អត្ថបទសារព័ត៌មានទាំងនេះ គួរត្រូវបានចាត់ទុកជាឯកសារភស្តុតាង ជាជាងភស្តុតាងបានមកពីសក្ខីកម្មទៅវិញនោះ។ ចំពោះការណ៍ដែលថា អត្ថបទសារព័ត៌មាន ដែលរួមមានសេចក្ដីថ្លែងការណ៍មុនៗរបស់ជនជាប់ចោទនោះ សេចក្ដីថ្លែងការណ៍ទាំងនេះ គឺអាចទទួលយកបានទេ ដោយអនុលោមតាមវិធានត្រឹមត្រូវតាមផ្លូវច្បាប់ដែលគ្រប់គ្រងទៅលើការទទួលយកសេចក្ដីថ្លែងការណ៍មុនៗ ដោយមិនគិតពីទម្រង់ដែលលេចឡើង។

៤៧- ទាក់ទិននឹងសម្ភារៈដែលមិនកើតឡើងក្នុងពេលដំណាលគ្នាទាំងអស់ (រួមមាន សៀវភៅ របាយការណ៍វិភាគ ខ្សែភាពយន្តឯកសារ និងអត្ថបទសារព័ត៌មាន) សារណាណាមួយធ្វើឡើង

[71] *រឿងក្ដីរវាង រដ្ឋអាជ្ញា តទល់នឹង Radoslav Brđanin* សំណុំរឿងលេខ IT-99-35-T សាលក្រម ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៤ ត្រង់កថាខណ្ឌ ៣៣ (បញ្ជីឯកសារច្បាប់)។

ដោយមេធាវីការពារក្ដីចំពោះសច្ចភាពនៃព័ត៌មានដែលមាននៅក្នុងសម្ភារៈអ្វីមួយ អាចនឹងត្រូវបានដោះស្រាយយ៉ាងគ្រប់គ្រាន់ដោយអង្គជំនុំជម្រះនៅដំណាក់កាលក្រោយណាមួយ គឺពេលណាអង្គជំនុំជម្រះកំណត់ទៅលើទម្ងន់នៃភស្តុតាងដែលមាននៅក្នុងចំពោះសម្ភារៈនោះ។

៤៨- ចុងក្រោយបំផុត គួរកត់សម្គាល់ថា អត្ថបទសារព័ត៌មានចំនួនប្រាំមួយ (៦) ក្នុងចំណោមអត្ថបទសារព័ត៌មានដែលស្ថិតនៅក្នុងបញ្ជីឯករបស់សហព្រះរាជអាជ្ញា ដែលត្រូវបានយោងនៅក្នុងលេខយោងជើងទំព័រនៃកថាខណ្ឌក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលអង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញនោះ នឹងត្រូវអាននៅមុនការចោទសួរជនជាប់ចោទ។ អាស្រ័យហេតុនេះ យោងតាមសេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង នៅពេលដែលកថាខណ្ឌពាក់ព័ន្ធទាំងនេះត្រូវបានអានរួចរាល់ហើយ អត្ថបទសារព័ត៌មានទាំងនេះនឹងត្រូវបានពិចារណាថាត្រូវបានទទួលយក ដោយមិនមានសេចក្ដីសម្រេចផ្សេងពីនេះទៀតឡើយ[72]។

## vi. ឯកសារដែលមិនអាចចូលមើលបាន (ឯកសារបកប្រែ ឯកសារថ្មី និងឯកសារសម្ងាត់បំផុត)

៤៩- ខៀវ សំផន ជំទាស់ទៅនឹងឯកសារដែល "មិនអាចចូលមើលបាន" ដែលអាចមកពីមូលហេតុថាឯកសារទាំងនោះជាឯកសារសម្ងាត់បំផុត ដែលមិនទាន់ដាក់ទៅក្នុងសំណុំរឿង និងមិនទាន់បានបង្ហាញនៅឡើយ ឬដោយសារមិនទាន់មានជាភាសាខ្មែរ និងភាសាបារាំង (ដែលជាភាសាផ្លូវការរបស់ក្រុមអ្នកច្បាប់របស់គាត់)[73]។ អៀង សារី ក៏បានលើកឡើងនូវកង្វល់ទាក់ទងទៅនឹងឯកសារនៅក្នុងបញ្ជីឯកសារដែលមិនទាន់បានបកប្រែទៅជាភាសាខ្មែរ និងភាសាអង់គ្លេស (ដែលជាភាសាផ្លូវការរបស់ក្រុមអ្នកច្បាប់របស់គាត់) ឬដែលមិនទាន់បានបង្ហាញជូនភាគីទាំងអស់នៅឡើយនោះ[74]។

ឯកសារសម្ងាត់បំផុត

៥០- មិនមានឯកសារនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ត្រូវបានចាត់ចំនាត់ថ្នាក់ថាសម្ងាត់

[72] សូមមើលឧបសម្ព័ន្ធ ក និង *លេខជើងទំព័រយោង* ២៩ *ខាងលើ*។

[73] ឯកសារ **E131/6** ការជំទាស់របស់លោក ខៀវ សំផន *លេខជើងទំព័រយោង ១៥ ខាងលើ* ត្រង់កថាខណ្ឌ ៣៩-៤៥។

[74] ការជំទាស់របសល់លោក អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារជាក់លាក់មួយចំនួន *លេខជើងទំព័រយោង* ១២ និង ៥ *ខាងលើ*។

បំផុតនោះទេ។ ហេតុដូច្នេះ ការជំទាស់តវ៉ារបស់ ខៀវ សំផន គឺមិនត្រឹមត្រូវនោះទេ។ គួរកត់សម្គាល់ផងដែរថា ថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយបញ្ហានៃលទ្ធភាពចូលមើលឯកសារសម្ងាត់[75]។

ឯកសារថ្មី

៩១- មានឯកសារចំនួនសែសិបបួន (៤៤) ច្បាប់នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដែលសរសេរថា "ឯកសារថ្មី"។ ក្នុងចំណោមឯកសារទាំងអស់នេះ មានឯកសារចំនួនពីរ (២) ច្បាប់[76] គឺជាសេចក្ដីដកស្រង់ចេញពីឯកសារដែលមានក្នុងសំណុំរឿង និងបានផ្ដល់លេខយោងរួចហើយ ហើយឯកសារចំនួនម្ភៃបួន (២៤) ច្បាប់ក៏ត្រូវបានផ្ដល់ជូនភាគីទាំងអស់នៅក្នុងឃ្លាំងផ្ទុកឯកសាររួម (Shared Materials Drive) ហើយដែរ។ ភាគីទាំងអស់អាចចូលមើលឯកសារផ្សេងទៀតនៅក្នុងឃ្លាំងផ្ទុកឯកសាររួម នៅក្នុងសំណុំឯកសារឈ្មោះថា "ឯកសារថ្មីរបស់ ក.ស.ព សម្រាប់សំណុំរឿង ០០២"។

ឯកសារដែលពុំមានជាភាសាការងារទាំងពីររបស់ក្រុមមេធាវីការពារក្ដី

៩២- មេធាវី ការពារក្ដីពុំមានសិទ្ធិដាច់ខាតក្នុងការស្នើសុំបកប្រែឯកសារទាំងអស់ជាភាសា ការងារទាំងពីររបស់ខ្លួននៅមុនសវនាការឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថាឯកសារដែលត្រូវបង្ហាញក្នុងសំណុំរឿង ០០២ "ជាទូទៅ" គួរតែមានជា ៣ ភាសាផ្លូវការនៅ អ.វ.ត.ក[77]។ ពាក្យពេចន៍ដ៏មានសារៈសំខាន់នេះមានន័យថាឯកសារដែលពុំមានជាបីភាសា អាចត្រូវលើកយកមកបង្ហាញនៅក្នុងស្ថានភាពណាមួយ។ នេះជាវិធីសាស្ត្រដែលធ្លាប់បានអនុវត្តក្នុងសំណុំរឿង ០០១ នៅពេលអង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា ខ្លួនសុខចិត្តទទួលយកឯកសារដែលមានតែជាភាសាខ្មែរ និងភាសាផ្លូវការមួយទៀតនៅ អ.វ.ត.ក[78]។ ក្នុងការអនុវត្តវិធីសាស្ត្រនេះ អង្គជំនុំជម្រះ

[75] ឯកសារ **E118/4** ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើរបស់មេធាវីការពារក្ដីជនជាប់ចោទ អៀង សារី ដែលស្នើសុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[76] ឯកសារលេខ ៣៧២ និងកថាខណ្ឌ ៣៧៤ នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា។

[77] ឯកសារ E131/1 អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង *កថាខណ្ឌខាងលើ*លេខ៨ នៅត្រង់ទំព័រ៣។

[78] ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ៣២ (សំណុំរឿងលេខ០០១)

សាលាដំបូងបានលើកឡើងថាធនធានផ្នែកបកប្រែនៅ អ.វ.ត.ក នៅមានកម្រិត ហើយសំណុំរឿងមានវិសាលភាពទូលំទូលាយ[79]។

៩៣- លើករណីសំណុំរឿង អង្គបុរេជំនុំជម្រះក៏បានបញ្ជាក់ថាពុំមានឡើយសិទ្ធិស្វ័យប្រវត្តដែលតម្រូវ ឲ្យរាល់ឯកសារទាំងអស់ក្នុងសំណុំរឿងត្រូវមានជាពាភាសាផ្លូវការ[80]។ ក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គបុរេជំនុំជម្រះបានសំអាងទៅលើយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ក្នុងនោះមានតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ផងដែរ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បានសម្រេចថា គោលការណ៍នៃយុត្តិធម៌ពុំ "ផ្តល់ឲ្យ [ជនជាប់ចោទ] នូវសិទ្ធិដែលតម្រូវឲ្យមានការបកប្រែរាល់ឯកសារនីតិវិធី និង ភ័ស្តុតាងសម្ភារៈទាំងអស់ដែលភាគីអយ្យការបានបង្ហាញឡើយ"[81]។ ក្រៅពីក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះក៏បានកត់សម្គាល់ឃើញថាជនជាប់ចោទក៏បានទទួលការអនុញ្ញាតឲ្យមាន "ជំនួយឥតគិតថ្លៃ និងពេញម៉ោងពីសំណាក់អ្នកបកប្រែ ដើម្បីធ្វើយ៉ាងណាឲ្យជនជាប់ចោទ និងក្រុមមេធាវីការពារក្តីអាចទទួលបានឯកសារបកប្រែតាមការចាំបាច់ក៏ដូចជាដើម្បីវាយតម្លៃលក្ខខណ្ឌបកប្រែរបស់ក្រុមមេធាវីការពារក្តីសម្រាប់ជូនដំណឹងទៅផ្នែកគ្រប់គ្រងតុលាការ និងជួយសម្រួលកិច្ចសហការរវាងក្រុមមេធាវីការពារក្តី ជាមួយផ្នែកគ្រប់គ្រងតុលាការ"។

---

[79] *ដូចជើងទំព័រខាងលើ*។

[80] ឯកសារ A190/I/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីពីសាលដីកាលើរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ នៅត្រង់កថាខណ្ឌ២៤-៤៩។ ឯកសារ A190/I/20 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ នៅត្រង់កថាខណ្ឌ៤១-៥០។

[81] *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Lubanga* សំណុំរឿង ICC-01/04-01/06, "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ចុះថ្ងៃទី ៣ និងទី ៤ ខែ កក្កដា ឆ្នាំ ២០០៦", អង្គបុរេជំនុំជម្រះ I, ចុះថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០០៦ ត្រង់ទំព័រ ៦។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថាសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ពុំរងការរំលោភដោយសារតែពុំមានឯកសារទាំងអស់នៅក្នុងសំណុំរឿងរបស់ជនជាប់ចោទ មានជាភាសាដែលជនជាប់ចោទចេះឡើយ៖ *Kamasinski*។

៥៤- គួរកត់សម្គាល់ថាមកទល់នឹងថ្ងៃដាក់ឯកសារនេះ មានឯកសារចំនួន ១៦ ប៉ុណ្ណោះ[82] នៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា ដែលពុំទាន់មានជាភាសាខ្មែរ ឬភាសាបារាំង ដែលជាភាសាការងារទាំងពីររបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន។ មានឯកសារចំនួនតែមួយប៉ុណ្ណោះ[83] ដែលពុំទាន់មានជាភាសាអង់គ្លេស និងភាសាបារាំង ដែលជាភាសាការងារទាំង ២ របស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី។ សហព្រះរាជអាជ្ញាបានស្នើទៅផ្នែកគ្រប់គ្រងតុលាការ សុំឱ្យបកប្រែរាល់ឯកសារទាំងអស់ដែលមាននៅក្នុងបញ្ជីរបស់ខ្លួនក្នុងប្រភេទជាបញ្ហាអាទិភាព ហើយសំណោបកប្រែថ្មីៗកំពុងត្រូវបានដាក់បន្ថែមចូលទៅក្នុងសំណុំរឿងស្ទើររៀងរាល់ថ្ងៃ។

### *vii. ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងឯកសារដែលពុំមានបញ្ជាក់យថាភាព*

៥៥- ជនជាប់ចោទ ខៀវ សំផន ព្រួយបារម្ភអំពីយថភាព និងដំណើររក្សាឯកសាររបស់មជ្ឈមណ្ឌលឯកសារ កម្ពុជានិងបានស្នើទៅអង្គជំនុំជម្រះសាលាដំបូងសុំឱ្យ "ទទួលយកឯកសារដើម និងបញ្ជាក់យថាភាពនៃឯកសារទាំងនោះ និងកំណត់លក្ខខណ្ឌថាខ្លឹមសារនៃឯកសារទាំងនោះត្រូវតែការបញ្ជាក់ការពិតដោយភស្តុតាងផ្សេងទៀត"[84]។ ជនជាប់ចោទ អៀង សារី ក៏ធ្លាប់បានជំទាស់ទៅនឹងការទទួលយកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយសំអាងថាមានភាពលម្អៀង[85]។ ជនជាប់ចោទ នួន ជា បានជំទាស់ទៅនឹងការទទួលយក "ឯកសារទាំងឡាយណាដែលពុំទាន់បានបញ្ជាក់យថាភាពដោយភាគីដាក់ឯកសារ (ឬដោយអង្គជំនុំជម្រះ ប្រសិនបើខ្លួនសំអាងលើសម្ភារៈឯកសារ *តាមគំនិតអត្តនោម័ត*")[86]។

---

[82] ឯកសារ D366/7.1.820 (ឯកសារ19)។ ឯកសារ D56-document.137 (ឯកសារ 21); ឯកសារ 41; ឯកសារ 84; D366/7.1.824 (ឯកសារ 484); ឯកសារ 498; D313/1.2.52 (ឯកសារ 508); ឯកសារ 528; ឯកសារ 669; ឯកសារ 868; D108/31.20 (ឯកសារ 646); ឯកសារ 686; ឯកសារ 667; D108/26.281 (ឯកសារ 913); ឯកសារ 926; ឯកសារ 927.

[83] ឯកសារ D56-Doc. 137 (ឯកសារ 21).

[84] ឯកសារ **E131/6** ការជំទាស់របស់លោក ខៀវ សំផន *កថាខណ្ឌខាងលើ*លេខ១៥ នៅត្រង់កថាខណ្ឌ៤៦-៧។

[85] ឯកសារ **E114** ការជំទាស់របស់លោក អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារជាក់លាក់មួយចំនួន *កថាខណ្ឌខាងលើ*លេខ១២ នៅត្រង់កថាខណ្ឌ១៤ និងឯកសារ **E114/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "ការជំទាស់របស់ អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារមួយចំនួន" *កថាខណ្ឌខាងលើ*លេខ១៤ នៅត្រង់៣០-៣៨។

[86] ឯកសារ **E131/1/9** ការជំទាស់ការកត់សម្គាល់ និងការជូនដំណឹងទាក់ទងនឹងឯកសារផ្សេងៗដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង *កថាខណ្ឌខាងលើ*លេខ១៦ នៅត្រង់១៩។

៥៦- គួរកត់សម្គាល់ថាថ្វីបើជនជាប់ចោទ ខៀវ សំផន ធ្លាប់បារម្ភខ្លាចក្រែងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមិនអាចយកជាការបានក៏ដោយ ក៏ជនជាប់ចោទបានស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកឯកសារចំនួន ៣៥ ដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា[87]។ នេះជាចំណុចគួរពិចារណាអំពីសុពលភាពគតិយុត្តិនៃការជំទាស់របស់គាត់។

៥៧- សហព្រះរាជអាជ្ញាធ្លាប់បានស្នើជាលាយលក្ខណ៍អក្សរ ស្តីពីលក្ខខណ្ឌអនុវត្តសម្រាប់ការទទួលយកភស្តុតាងចំពោះមុខ អ.វ.ត.ក[88]។ សហព្រះរាជអាជ្ញាសូមដាក់បញ្ចូលសំណើទាំងនេះជាឯកសារយោង ដោយពុំបរិយាយលម្អិតឡើយ។ ជាសង្ខេប សហព្រះរាជអាជ្ញាសូមរំឭកថាដើម្បីឱ្យ អ.វ.ត.ក ទទួលយកភស្តុតាងណាមួយ ភស្តុតាងនោះត្រូវបំពេញ "បទដ្ឋានអប្បបរមានៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន"។ លក្ខខណ្ឌនេះអនុវត្តចំពោះរាល់ភស្តុតាងឯកសារទាំងអស់ និងស្របតាមវិធីសាស្ត្ររបស់បណ្តាតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានាផងដែរ។

៥៨- នៅ អ.វ.ត.ក ឬនៅតុលាការផ្សេងឯទៀត ពុំមានវិធានណាមួយតម្រូវឱ្យចងក្រងឯកសារដើមដោយពុំគិតអំពីកាលៈទេសៈឡើយ។ នៅពេលពុំមានឯកសារដើម ភាគីអាចបង្ហាញឯកសារថតចម្លងក៏បាន នៅក្នុងសំណុំរឿងបច្ចុប្បន្ន ឯកសារចំនួនភាគច្រើនលើសលប់ក្នុងសំណុំរឿងគឺទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយឯកសារដើមនៃឯកសារទាំងអស់នេះទៀតសោតត្រូវបានតម្កល់ទុកនៅកន្លែងមានសុវត្ថិភាពជាច្រើនកន្លែង។ ការទាមទារឱ្យចងក្រងឯកសារដើមចំនួនរាប់ពាន់នេះ នឹងធ្វើឱ្យសវនាការជាប់គាំង។ នៅពេលមានមន្ទិលពាក់ព័ន្ធនឹងយថាភាពនៃឯកសារណាមួយ មន្ទិលទាំងនោះគួរត្រូវបានវាយតម្លៃទៅតាមករណីនីមួយៗយោងតាមលក្ខខណ្ឌនៃភាពអាចជឿជាក់បាន។

---

[87] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 20.3, D248/3.3, D366/7.1.157, IS 3.1, IS 21.140, D161/1.9, D161/1.4, IS 21.147, D279/6.3, D161/1.25, D161/1.21, D161/1.20, D161/1.7, IS 21.142, D161/1.13, D161/1.31, D161/1.14, D161/1.30, D279/6.12, D279/7.4, NA (សៀវភៅរបស់ YEN), D175/3.17, IS 21.74, NA (ឯកសារសម្ភាសន៍ស៊ុយអ៊ែត), D366/7.1.283, IS 13.11, IS 13.2, IS 13.14, D56-Doc, D248/6.1.2, D279/7.11, D175/3.77, D210/5, D210/5R, D161.1.50។ ក្នុងចំណោមនោះ មានឯកសារចំនួន ២ អាចសម្គាល់ថាជាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈលេខនៅផ្នែកខាងស្តាំខាងលើ។

[88] សូមមើលជារួម **E114/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "ការជំទាស់របស់ អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារមួយចំនួន" *កថាខណ្ឌខាងលើ*លេខ១៤ នៅត្រង់កថាខណ្ឌ៨-១២។

៩៩- ពុំមានលក្ខខណ្ឌតម្រូវឱ្យមានបញ្ជាក់ពីយថាភាពនៃឯកសារដែល "ត្រូវបានបង្ហាញយ៉ាងពិតប្រាកដ" ដូចដែលបានលើកឡើងដោយ នួន ជា ឡើយ។ ផ្ទុយទៅវិញ ភ័ស្តុតាងត្រូវតែបង្ហាញពីការទទួលខុសត្រូវឱ្យបានពេញលេញ (ដែលចាត់ទុកថាការទទួលខុសត្រូវទាំងស្រុង) ទើបអាចទទួលយកបាន។ ភស្តុតាងដែលបញ្ជាក់ពីលក្ខណៈដើមនៃឯកសារ និងដំណើរការទុកដាក់ឯកសារនឹងពាក់ព័ន្ធនៅពេលពិចារណាថា តើឯកសារមួយបានបង្ហាញពីការទទួលខុសត្រូវពេញលេញឬទេ តែពុំមែនបង្ហាញពីបុរេនិច្ឆ័យដើម្បីអាចទទួលយកបាននោះឡើយ។ មានអ្នកផ្តល់ទស្សនៈសំខាន់ម្នាក់ ដែលបានលើកឡើងនូវច្បាប់យុត្តិសាស្ត្រពីតុលាការព្រហ្មទណ្ឌអន្តរជាតិ (ដែលតុលាការនេះមួយចំនួនធ្លាប់បានដកស្រង់មកសំអាងដោយសហព្រះរាជអាជ្ញារួចមកហើយ)[89] បានសង្ខេបពីតួនាទីនៃយថាភាពរបស់ឯកសារដូចខាងក្រោមថា៖

> *ភាគីដែលដាក់ឯកសារ ដែលជាផ្នែកនៃការបង្ហាញការទទួលខុសត្រូវ ត្រូវគេរំពឹងថានឹងផ្តល់នូវសញ្ញាណខ្លះៗរបស់ឯកសារនោះ ហើយថាឯកសារជាឯកសារពិត។ លក្ខខណ្ឌតម្រូវនេះជាញឹកញយត្រូវបានគេចាត់ថាជា "ការបញ្ជាក់យថាភាព" តែទស្សនាទាននេះពុំមានទំនាក់ទំនងទៅនឹងទស្សនាទានបច្ចេកទេសនៃការបញ្ជាក់យថាភាពនៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់ប្រទេសមួយចំនួនទេ។ ការបញ្ជាក់យថាភាពនៅក្នុងតុលាការអន្តរជាតិពុំមានអ្វីលើសពីករណីដែលថា "ឯកសារនោះ" ជាអ្វីដែលភាគីស្នើយកមកធ្វើជាសំអាងដើម្បីបង្ហាញពីការទទួលខុសត្រូវនោះទេ។ ឧទាហរណ៍ អ្នករៀបរៀង ឬអ្នកគ្រប់គ្រងឯកសារពុំចាំបាច់ផ្តល់សក្ខីកម្មនៅក្នុងតុលាការចំពោះឯកសារដែលត្រូវបានបញ្ជាក់យថាភាពហើយនោះទេ ហើយក៏ពុំចាំបាច់ឱ្យមានទទួលស្គាល់ ឬមានយោបល់ដោយសាក្សីណាទៀតឡើយ។ គេពុំចាំបាច់ឱ្យមានការបង្ហាញពីការគ្រប់គ្រងឯកសារ ហើយជាញឹកញយ អំណះអំណាងអំពីប្រភពឯកសារដោយភាគីខ្លួនឯងនឹងត្រូវបានទទួលស្គាល់ដោយយោងទៅលើសក្ខីកម្មដោយផ្ទាល់ ឬការអះអាងដោយអ្នកស៊ើបអង្កេត[90]។*

[89] ដូចជើងទំព័រខាងលើ។

[90] Christopher Gosnell, ការទទួលយកភ័ស្តុតាងនៅក្នុងសំណុំរឿង Khan និងអ្នកផ្សេងទៀត, *គោលការណ៍ភ័ស្តុតាងនៅតុលាការឧក្រិដ្ឋកម្ម អន្តរជាតិ* (២០១០) ត្រង់ទំព័រ ៣៨៧-៣៨៨ (លុបចោលឯកសារយោង)។

៦០- តាមការបញ្ជាក់ក្នុងផ្នែកទី I ខាងលើ សេចក្តីសន្និដ្ឋានលម្អិតអំពីលក្ខខណ្ឌនៃភាពអាចជឿជាក់បាននៃឯកសារសម្រាប់ឯកសារទាំងអស់ក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា នឹងត្រូវបានដាក់នៅពេលឆាប់ៗខាងមុខដោយអនុលោមតាមវិធាន ៩២។ ថ្វីបើសហព្រះរាជអាជ្ញាពុំយល់ថាពុំចាំបាច់មានសេចក្តីសន្និដ្ឋាននេះក៏ដោយ ក៏ការដាក់សេចក្តីសន្និដ្ឋាននេះមានភាពចាំបាច់ ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងពិចារណាលើការជំទាស់(ទូទៅ)នានា ពាក់ព័ន្ធនឹងឯកសារទាំងនេះ ដែលត្រូវបានលើកឡើងរួចហើយ ឬការជំទាស់ណាមួយដែលអាចត្រូវបានលើកឡើងនៅថ្ងៃមុខ។

## IV. **ដំណោះស្រាយ**

៦១- តាមហេតុផលដូចដែលបានបញ្ជាក់ខាងលើ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងឲ្យ៖

(១) បង្គាប់ឲ្យមេធាវីការពារក្តីដាក់ម្តងទៀតនូវសេចក្តីជំទាស់ជាក់លាក់ ប្រសិនបើមាន ទៅនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដោយបញ្ជាក់បង្ហាញអំពីឯកសារណាមួយដែលខ្លួនជំទាស់ និងហេតុផលនៃការជំទាស់ ឲ្យបានត្រឹមថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១

(២) ទទួលយកឯកសារនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដែលពុំមែនជាកម្មវត្ថុនៃការជំទាស់ដែលមានសំអាងហេតុជាក់លាក់ និង

(៣) កំណត់កាលបរិច្ឆេទសវនាការសម្រាប់ទាញហេតុផលផ្ទាល់មាត់ ចំពោះការជំទាស់ណាមួយដែលមានហេតុផលជាក់លាក់ ដែលអង្គជំនុំជម្រះបានទទួល។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |